# អ្នកតាឃ្លាំងមឿង

## ជា ឧបាយបញ្ឆោត នៃ ប្រវត្តិសាស្ត្រ ?



មន្ត្រីខ្មែរ ជំនាន់ដើម

សរសេរ ដោយ ឧប សៅ សង្ហា

គ្មាន រក្សាសិទ្ធិ អ្នកនិពន្ធ

# អ្នកតាឃ្លាំងមឿង

**មាតិការឿង**


អារម្មណ៏កថា.......... 3

តា ឃ្លាំងមឿង .......... 5

អត្ថធិប្បាយ ជា មតិផ្ទាល់ខ្លួន .......... 14

**ការបូជាជីវិត របស់ តាមឿង.......... 14**

តើជារឿងពិត ដែរឬទេ ?.......... 16

**តើ ហេតុអ្វីបានជា តាមឿង មិនជួយ ព្រះស្រីសុគន្ធបទ ?.......... 20**

**សង្ខេប ប្រវត្តិសាស្ត្រ.......... 22**

**សន្តរាជវង្ស ព្រះបាទ ពញាយ៉ាត .......... 26**

**ព្រះស្រីសុគន្ធបទ .......... 30**

**ស្តេចកន .......... 35**

**ព្រះចន្ទរាជា .......... 42**

# អ្នកតាឃ្លាំងមឿង

## អារម្ភណ៏កថា

ប្រវត្តិ នៃ អ្នកតា ឃ្លាំងមឿង មាន ស្នាមនៅក្នុង ប្រវត្តិសាស្ត្រ ខ្មែរ នៅក្នុងសតវត្ស ទី១៦ កើតមានឡើង នៅក្នុង ប្រវត្តិសាស្ត្រ ព្រះចន្ទរាជា និង ស្តេចកន ដែលជា ព្រឹត្តិការណ៍ ដ៏សំខាន់មួយ។ របបរាជានិយម តែង ទុក ស្តេចកន ជា ជន ក្បត់ រាជបល្ល័ង្ក និង អ្នកតា ឃ្លាំងមឿង ជា វិរបុរស។ អ្នកតា ឃ្លាំងមឿង ជា អ្នក គាំពារ ព្រះចន្ទរាជា ដែល ជា ស្តេច ធ្វើសង្គ្រាម ប្រឆាំងនឹង ស្តេចកន។ តែ ក្នុង អារម្មណ៍ខ្មែរមួយភាគ តែង ទុក ស្តេចកន ជា និមិត្តរូប នៃ ការតស៊ូរ វណ្ណៈ ឬ ការបះបោរ ប្រជាជន ប្រឆាំង នឹង របប រាជានិយមផ្តាច់ការ។

នៅ ក្នុង អត្ថបទ នេះ ខ្ញុំ គ្មាន បំណង យក ព្រឹត្តិការណ៍ ស្តេចកន និង អ្នកតា ឃ្លាំងមឿង មក សរសេរ ជា ការសិក្សា ប្រវតិសាស្ត្រ នោះឡើយ តែ សាកល្បង ធ្វើ វិភាគ ចង់ យល់ដឹង អំពី ការពិត ដែល មាន កើតឡើង នៅ ក្នុង ព្រឹត្តិការណ៍នោះ។ ហេតុ នេះឯង ខ្ញុំ សូម អ្នកអាន មេត្តា អភ័យទោស ពី ការសាកល្បង ជា មតិផ្ទាល់ខ្លួន នៅទីនេះ។

ប្រលោមលោក ប្រវត្តិសាស្ត្រ មាន ច្រើន ខ្លះដែរ នៅ ស្រុកខ្មែរ។ ប្រលោមលោក ដែល ល្បី មួយ នៅ ក្នុង សម័យ កុមារភាពខ្ញុំ គឺ រឿង ព្រះចន្ទរាជា និព័ន្ធ ដោយ កវី បីវ ឆៃលាង។ លោក បាន យក ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ មកតាក់តែង សេសេរ ជា

# អ្នកតាឃ្លាំងមឿង

ប្រលោមលោក ទាក់ទាញ អារម្មណ៍ អ្នកអាន អោយ រស់ នៅ ក្នុង សាច់រឿង ដូច ខ្លួន ជា តួ សកម្ម មួយ នោះ ដែរ។ រឿង ព្រះចន្ទរាជា របស់ កវី បីរ ឆីលាង បង្ហាញ នូវ រូបភាព ស្តេចកន ជា ជន ក្បត់ រាជបល្ល័ង្កល រីឯ ព្រះចន្ទរាជា និង អ្នកតា ឃ្លាំងមឿង វិញ ជាវិរបុរសជាតិ ដែល ស្របនឹង ទស្សនកថា ជា ផ្លូវការ នៃ របប រាជានិយម ដែល ជា របប ដែល អ្នក និព័ន្ធ រស់នៅ ក្នុង ពេលដែល គាត់ សរសេរ ប្រលោមលោក នោះ។

ចំពោះ ខ្ញុំ វិញ, ខ្ញុំ មិនកាន់ជើង ខាងណាឡើយ តែ គ្រាន់តែ បង្ហាញ តាម ការយល់ឃើញ របស់ខ្ញុំផ្ទាល់ ថា អំពើណា ដែល ជា អំពើ អវិជ្ជមាន និង វិជ្ជមាន សំរាប់ ជាតិខ្មែរ ព្រោះ ជម្លោះ រវាង ព្រះចន្ទរាជា ជាមួយ ស្តេចកន វា មាន លក្ខណ: ជា ជម្លោះ រវាង បុគ្គល នឹង បុគ្គល, វណ្ណ: និង វណ្ណ: និង នយោបាយ ផង។ ហេតុ នេះឯង អ្វី ដែល ខ្ញុំ លើកមក បង្ហាញ វា អាច ជា ចំណុច រសើប ចំពោះ អ្នកអាន ដែល មាន គោលនិយម លំអៀង ទៅ រក ខាង ណាមួយ ដូច្នេះ សូម អ្នកទាំងនោះ ទុក ការសាកល្បង របស់ខ្ញុំ ជា គំនិត អព្យាក្រឹត ឈរ លើ មូលដ្ឋាន អក្សរសាស្ត្រ គឺ សេរីភាព នៃ ការនិព័ន្ធ សំរាប់ តែ បំរើ វិចិត្រសិល្ប: តែប៉ុណ្ណោះ។

ការវិភាគ នៅ ទីនេះ គឺ ខ្ញុំ យក ឯកសារ លោក អេង សុត ជា មូលដ្ឋាន។ ឯកសារ នោះ មាន ចំណងជើង ថា ‹‹មហាបុរសខ្មែរ-ព្រះរាជពង្សាវតាខ្មែរ››។ លោក អេង សុត ជា សមាជិក នៃ គណកម្មការ ប្រវត្តិសាស្ត្រ និង វប្បធម៌ ខ្មែរ។ លោក មាន អាជីព ជា

ទៅក្រុមប្រឹក្សា សាលាវិនិច្ឆ័យ។ ឯកសារ នេះ លោក បាន ចុះ ផ្សាយ នៅ ទស្សនវដ្តី ៧០ ដកស្រង់ពី ព្រះរាជពង្សាវតា សុទ្ធសាធ ដែល បុព្វបុរស ខ្មែរយើង លោក បាន សរសេរ ទុក ក្នុង ក្រាំង និង ចារ លើ ស្លឹករិត ដើម្បី ទុក ជា កេរ្តិ៍មរតក អោយ កូនខ្មែរ ជំនាន់ក្រោយ បានដឹង ហើយ យកទៅ បន្ត ពិចារណា រក ការ ពិត ដោយ ខ្លួនឯង ឱ្យ បាន ជាក់ច្បាស់ ដើម្បី ជា ចំណេះដឹង សំរាប់ខ្លួនឯងផង និង ប្រជាជាតិផង។

## តា ឃ្លាំងមឿង

នៅក្នុង សាស្ត្រាកំពង់ត្រឡាច មានកន្លែងខ្លះនិយាយថា តា មឿងនេះ មិនមែនឈ្មោះមឿង ឬ ឃ្លាំងមឿងដូច្នេះទេ គឺថា គាត់មានឈ្មោះ ជា ពេជ ដូច្នេះទៅវិញ។ គេនិយាយបែបនេះ ក៏ សមដែរ ព្រោះ តាមឿងនោះស្លាប់ទៅ ទៅកើត ជា អ្នកតាចាស់ ស្រុក ដែល សៀម ហៅថា ‹ខ្លាងមឿង› ហើយខ្មែរយើង ហៅថា តាម យារៗមក ជា ឃ្លាំងមឿង ដូច្នេះទេឬ ?

តាមឿង ជា ធនិក ម្នាក់ នៅ ខែត្រ ពោធិសាត់ ហើយ ក៏ជា មេស្នឹង[1]ផង។ គាត់ មាន កូនប្រុស ៤នាក់។ នៅពេល ដឹងដំណឹង ថា ព្រះចន្ទរាជា យាង មកដល់ ក្បែរភូមិ របស់គាត់ តាមឿង ក៏ ស្រូតរូតទៅថ្វាយបង្គំ ហើយ ក៏ដឹងរឿងហេតុ អំពី រាជដំណើរ ភៀសខ្លួន ទៅ ស្រុកសៀម, គាត់ ក៏ជួយឧបត្ថម្ភ ដោយ ថ្វាយ

[1] មេស្នឹង : មេខ្មោច។

# អ្នកតាឃ្លាំងមឿង

ដំរី ៨ និង សេះ ១០ ក្បាល និង ឱ្យ កូនប្រុស ទាំង ៤ នាក់ តាម ដង្ហែរ ព្រះចន្ទរាជា ទៅក្រុងទេព។ មកដល់ក្រុងទេព ព្រះចន្ទរាជា ទ្រង់ចូលគាល់ ព្រះចៅចក្រពត្តិ ស្តេចសៀម ហើយ ថ្វាយ ដំណឹងគ្រប់ប្រការ ពី ស្ថានការណ៍ នៅស្រុកខ្មែរ។ ព្រះចៅសៀម ទទួល ទំនុកបម្រុង ដល់ ស្តេចខ្មែរ ដោយ ប្រទានយសស័ក្តិ និង វាំងដំណាក់ ឱ្យ គង់ខាង វត្តប្រណែងធឿន ជាសុខរៀងមក។

នៅពេល ដែល ព្រះចន្ទរាជា វិលត្រឡប់មកស្រុកខ្មែរវិញ ដោយ មាន ទាហានសៀម ៥ ពាន់ នាក់ ដង្ហែរ ព្រះអង្គ ហើយ នៅ ពេល ទ្រង់ យាង មកដល់ ខែត្រ បាត់ដំបង ពញាមនោមេត្រី ចៅហ្វាយស្រុកនោះ បានដឹងថា ចៅពញាចន្ទរាជា ជា ព្រះរាជ ត្រកូលស្តេចខ្មែរ ត្រឡប់មកដល់ហើយ ក៏ចូលថ្វាយបង្គំ ថ្វាយ រេហ៍ពល ១ ម៉ឺន នាក់ និង ស្បៀងអាហារ ព្រមទាំង រទេះ ១ ពាន់ គ្រឿង ទៀត សំរាប់ ធ្វើសឹកសង្គ្រាម។ ទទួលបានជំនួយ រួច ហើយ ទ្រង់ ក៏លើកទ័ព ទៅតាំងបន្ទាយ នៅ ខែត្រពោធិសាត់។ រី តាមឿង វិញ លុះបានដឹងថា ចៅពញាចន្ទរាជា ស្តេចត្រឡប់ មកដល់ ស្រុក បាត់ដំបងហើយ ក៏ ដើរបញ្ចុះបញ្ចូល ស្ម័គ្របក្ស ពួក ចៅពញាសួគ៌ាលោក ចៅហ្វាយស្រុក ខែត្រពោធិសាត់ ដែល ជា មន្ត្រី ខាង ស្តេចកន ឱ្យងើបប្រឆាំងនឹងចៅហ្វាយខ្លួន។ ក្រោយបន្តិចមក តាមឿង បាននាំ បក្សពួក ដែលចូលខាង ខ្លួន ចូលលុក នៅវេលា យប់ស្ងាត់ មិនឱ្យដឹងខ្លួន ជាមុន ហើយ សម្លាប់ ចៅពញាសួគ៌ា នៅពេល ដែល គាត់កំពុងជំនុំ រាជការ

# អ្នកតាឃ្លាំងមឿង

តទទឹងនឹង ទ័ព ព្រះចន្ទរាជា។ បន្ទាប់មក តាមឿង បញ្ចុះបញ្ចូល ទាហាន ចំនួន ៤ ម៉ឺន នាក់ របស់ សព ពញាស្ទួគ៌ា ឱ្យចូលបំរើ ក្នុង កងទ័ព របស់ ព្រះចន្ទរាជា បានទាំងអស់។ បន្ទាប់មក គាត់ ទៅអញ្ជើញ ស្តេចខ្មែរ ឱ្យលើកទ័ព ចូលប្រថាប់ នៅក្នុង បន្ទាយ ស្រុកពោធិសាត់។ នៅទីនោះ ព្រះចន្ទរាជា ប្រកាស ហាម មិនឱ្យ ទាហានភូមិន្ទ ទាំងខ្មែរ ទាំងសៀម កំហែងកំហល់ រាស្ត្រប្រជា ឱ្យមានសេចក្តីក្តៅក្រហាយ, ទ្រង់ដាក់អាយ័តថា ‹បើ ឈ្មោះណាពុំស្តាប់ ព្រះរាជឱង្ការនេះទេ ស្តេចនឹងយកទោសដល់ជីវិត›។ ទ្រង់ តាំង តាមឿង ជា ‹ចៅពញា ស្ទួគ៌ាលោក› ជំនួស ចៅហ្វាយស្រុកខែត្រពោធិសាត់ចាស់ ដែលស្លាប់បាត់បង់ជីវិត។ កូនប្រុស ទាំង៤ របស់ តាមឿង ត្រូវបានតែងតាំង ឈ្មោះ កែវ ឱ្យធ្វើជា ‹ចៅពញាវង្សាអង្គរាជ ›, ឈ្មោះ កែ ឱ្យធ្វើជា ‹ចៅពញាបរទេសរាជ› ឈ្មោះ ទេព ឱ្យធ្វើជា ‹ចៅពញាវិបុលរាជ› កូនទី៤ ឈ្មោះ សុខ ឱ្យធ្វើជា ‹ចៅពញារាជតេជះ›។ ងារ ទាំងអស់នោះ គឺ ជា បាឡាត់ទ័ព មុខក្រោយ ឆ្វេងស្តាំ។ នាយទ័ព ទាំង៤ នាក់ ទទួល រាជបញ្ជា លើកទ័ព វាយបន្ទាយ ខែត្រក្រគរ បែក។ ដំណឹងអាក្រក់នេះ ឮដល់ ស្តេចកន ទ្រង់ ក៏បញ្ជា ឱ្យពញាចក្រី កេណ្ឌបណ្តារាស្ត្រ ខែត្រខាងលិច បង្កើត ជា កងទ័ព ហើយ លើក យ៉ាងស្រូតរូត ទៅបោះតាំងបន្ទាយ នៅ ខែត្រលង្វែក រួច រៀបចំ ធ្វើជា ទព័ស្រួច តទទឹងនឹងទ័ពព្រះចន្ទរាជា។ រីសម្តេចចៅហ្វា កៅ វិញជាមា របស់ស្តេចកន ធ្វើជា មេទ័ពធំ លើកទៅច្បាំងនឹងទ័ពសត្រូវ។ ចៅហ្វា កៅ

# អ្នកតាឃ្លាំងមឿង

នាំទ័ព ដើរតាមផ្លូវ ខែត្រកំពង់សៀម ឆ្ពោះទៅ ខែត្រពោធិសាត់។ ខ្សែកងទ័ពមួយទៀត ដឹកនាំដោយ ចៅហ្វាយ ខែត្រអាសន្ទុក លើកទ័ព កាត់សំដៅទៅ ខែត្របាត់ដំបង សំរាប់ ឆ្លងមកវាយផ្ទប់ពីក្រោយ កុំឱ្យ ព្រះចន្ទរាជា រត់រួច។

ទ័ព ចៅពញាចក្រី លើកមកដល់ ខែត្រក្រគរ ក៏ប្រទះនឹងទ័ពតាមឿង ហើយចូលច្បាំងគ្នា ដោយគ្មាន ការពន្យាពេល។ ទ័ពស្រួច ចំនួន ២ ពាន់នាក់ របស់តាមឿង មាន ពញាវង្សាអគ្គរាជ ជា នាយទ័ព កាលឃើញទ័ពសត្រូវ ក៏ស្រែកហ៊ោ យកជ័យ យ៉ាងកងរំពង ហើយ ក៏រត់សំដៅ ចូលលុកកងទ័ពនោះ វាយកាប់សម្លាប់គ្នា ពពាក់ពពូន ស្លាប់ហូរឈាម ដូចទឹកទរ ឬ ហូរដូចជាស្ទឹង តែ ទ័ពសត្រូវ មាន ចៅពញាតេជោ ជា នាយទ័ព មិនព្រមបែកសោះ។ ពញាវង្សាអគ្គរាជ ឃើញ ចៅពញាតេជោ នៅលើខ្នងសេះ ក៏ស្ទុះចូល ទៅដេញកាប់ យ៉ាងប្រយាប់ នាំឱ្យសេះ ពញាតេជោ ភ្ញាក់គេចខ្លួន ទៅប៉ះនឹងដើមឈើ បណ្ដាលឱ្យធ្លាក់ពីខ្នងសេះខ្លោក, ពញាវង្សាអគ្គរាជ ឃើញ សត្រូវ កំពុង ដេកលើដីក៏ស្ទុះទៅកាប់វា ស្លាប់មួយរំពេច តែ រេហ៍ពល ខាងសត្រូវ នៅបន្ត ប្រកាប់ប្រចាក់ ច្របូកច្របល់ ជាមួយ កងទ័ព តាមឿងយ៉ាងសាហាវ មិនព្រមចាញ់គ្នា ទៅវិញទៅមកសោះ។ ពញាវង្សាអគ្គរាជ គិតថា ទ័ពរបស់ខ្លួន មាន ចំនួន ទាហាន តិចជាង ទ័ពសត្រូវ បើនឹងបន្តច្បាំង ទៅទៀត ពុំបានឡើយ ក៏បញ្ជា ឱ្យទ័ពខ្លួន ដកថយ ពីសមរភូមិ តែ ចេញពុំរួច។ ចំណែក

# អ្នកតាឃ្លាំងមឿង

ទ័ព របស់ ពញាបរទេស និង ពញាវិបុលរាជ កូនប្រុស ទី២ និង ទី៣ របស់ តាមឿង បានជួបប្រទះនឹងទ័ពសត្រូវ ក៏ដេញពល ចូលច្បាំង កាប់ចាក់ ពល និង ពល, ចៅហ្វាយ និង ចៅហ្វាយ។ បន្តិចក្រោយមក ពញាវិបុលរាជ កាប់ត្រូវស្មា ចៅហ្វាយ ខែត្រ បាទី ជានាយទ័ពសត្រូវ បណ្ដាលឱ្យគាត់ពិការ ជា ទម្ងន់ ហើយ ត្រូវបាន សេនាទាហាន នាំគ្នាជួយគ្រាហ៍ ចៅហ្វាយខ្លួន រត់រួច ខ្លួនទៅ។ ដឹងដំណឹង មិនល្អនេះ ចៅបញាចក្រី ក៏លើកទ័ពធំ ឆ្ពោះទៅសមរភូមិ លុះឃើញកងទ័ព ចៅពញារាជាមេត្រី ជា នាយទ័ព ខាងខ្លួន កំពុង ច្បាំងនឹង ទ័ព កូន តាមឿង តែ នៅ ក្នុង ស្ថានភាព ចាញ់ប្រៀប ក៏បញ្ជា ឱ្យរេហ៍ពល របស់ខ្លួន ឱ្យ ចូលទៅជួយច្បាំងថែមទៀត រហូត ហ៊ុម ទ័ពភូមិន្ទ ជាប់។ តា មឿង ដឹងដំណឹងនេះភ្លាម ក៏លើកទ័ព ទៅជួយកូនទាំងពីរ យ៉ាងប្រញាប់។ ការប្រយុទ្ធ រវាង កងទ័ព ខាងចៅពញាចក្រី នឹង ខាងចៅពញាសួគ៌ាមឿង បានប្រព្រឹត្តទៅអស់រយៈពេលដ៏ យូរ តែមិនមានខាងណា អន់ជាងខាងណាឡើយ។ ទ័ព ទាំង សងខាង សុទ្ធសឹង តែរបឹងរឹងរូសមោះមុត ដូចៗគ្នា។ តែ យ៉ាង ហោចណាស់ តាមឿង អាច វាយរំដោះទ័ពកូនគាត់បាន តែ នឹកថប់ ថា ចំនួន ទ័ពសត្រូវ មាន ច្រើនក្រៃ ពុំអាចនឹងច្បាំង ឈ្នះគេបានឡើយ, លុះវេលាព្រលប់ មកដល់ហើយ តាមឿង ក៏ ឱ្យវាយស្គរ ជា សញ្ញាឱ្យដំណឹងដល់ កងទ័ព ដកទ័ពថយ វិលត្រ ឡប់ចូល បន្ទាយ។ ចៅពញាចក្រី ឃើញ ទ័ព តាមឿង ដកថយ តែ មិនហ៊ានដេញតាមទៅទេ ដោយខ្លាចចាញ់កលតាមឿង

# អ្នកតាឃ្លាំងមឿង

ដោយព្រះអាទិត្រ អស្តង្គត រលត់រស្មីទៅហើយផង។ លុះព្រឹកឡើង ចៅហ្វា កៅ ជា មា ស្តេច កន នាំ ទ័ព ៥ ម៉ឺន មកដល់ខែត្រ ក្រគរ ដឹង ថា តាមឿ ច្បាំង ចាញ់ ទ័ព ចៅពញាចក្រី ហើយ ដកទ័ព ទៅ ខែត្រ ពោធិសាត់ ក៏ ប្រមូលផ្តុំ ទ័ព តែមួយ មាន ចំនួន ទាំងអស់ ១ សែន នាក់ រួចក៏លើក ទៅច្បាំងនឹង ទ័ពភូមិន្ទ។ រី ទ័ព ព្រះចន្ទរាជា វិញ មាន ចំនួន ជាង ២ ម៉ឺន នាក់ តែប៉ុណ្ណោះ នៅ ការពារបន្ទាយជ័យ តស៊ូប្រយុទ្ធ ទប់ទល់ ពីការវាយប្រហារសត្រូវ ដូចស្រមោច រោម ស្ករ តែ វា វាយមិន បែក បន្ទាយ សោះឡើយ។ ត្រូវដឹងថា ព្រះចន្ទរាជា មាន ចំនួន ទាហាន តិចមែន តែ ក្នុងជួរទ័ព មាន យោធាអាជីពសៀម ៥ ពាន់ នាក់ មាន ការបង្ហឹកខាងផ្លូវសឹក រឹងប៉ឹងណាស់ ជួយ ច្បាំងព្រះអង្គ។ ចៅហ្វា កៅ គិត ថា នៅពេល វាយលុកចូលម្ដងៗ ទាហានខ្លួន ស្លាប់ជាច្រើនណាស់ ក៏ប្ដូរ យុទ្ធសាស្ត្រ ឱ្យពល ចោមព័ទ្ធ បន្ទាយ គ្រប់ ជ្រុង មិនឱ្យ ទ័ព របស់ ព្រះចន្ទរាជា ចេញរួច ឱ្យអត់បាយ បរិភោគ ដរាបដល់ស្លាប់។ ការឡោមព័ទ្ធ នោះ មាន រយៈពេល ១២ ខែ ហើយ ចាប់ផ្ដើម មាន អនុភាព អវិជ្ជមាន ទៅលើ កងទ័ពភូមិន្ទ នៅក្នុង បន្ទាយ ដោយ ស្បៀង អាហារ ក៏ចេះតែហោចទៅ។ តែ ទ័ព របស់ ចៅហ្វា កៅ ក៏មាន បញ្ហា ស្បៀង ចិញ្ចឹម ទាហាន ច្រើនក្រៃ ដោយ កងជញ្ជូនស្បៀង បញ្ជូនមកពុំទាន់។ នៅក្នុង ស្ថានភាព ធ្ងន់ធ្ងរ បែបនេះ ចៅហ្វា កៅ ក៏ធ្វើសេចក្ដីសម្រេច ឱ្យថយកងទ័ព មកតាំង បន្ទាយ ឆ្ងាយ ពីបន្ទាយ ព្រះចន្ទរាជា ចម្ងាយ ៣ សិន ដើម្បី ឱ្យកងទ័ព

# អ្នកតាឃ្លាំងមឿង

ផ្លាស់ប្ដូរគ្នា ចេញទៅរកស្បៀងអាហារ ក្នុង ភូមិជិតខាង។ ព្រះចន្ទរាជា និង តាមឿង មើលឃើញ ថា កងទ័ពសត្រូវ ថយឃ្លានពីបន្ទាយ របស់ខ្លួនហើយ ក៏គិតគ្នា ថា ជា ឱកាសល្អប្រពៃដើម្បី វាយ រំដោះខ្លួន ចេញពីបន្ទាយ។ តាមឿង ក្រាបទូល ព្រះចន្ទរាជា ថា៖ បើយើងនឹងវាយចេញ នោះក៏អាច ចេញរួចបានដែរ តែទ័ពយើង មាន ចំនួន តិចណាស់ ដោយ ប្រៀបធៀបនឹង ទ័ពសត្រូវ ដែលនឹងនាំឱ្យ ទាហានយើង ស្លាប់ច្រើនជាមិនខាន តែបើ បន្ត នៅក្នុងបន្ទាយ ក៏នឹង អត់បាយ ស្លាប់ជាមិនខានដែរ ដូច្នេះ ទូលបង្គំ ជា ខ្ញុំ គិតយកគំនិតមួយ មកសូមទទួលអាសា គឺ ទៅកេណ្ឌកងទ័ពបិសាច ឱ្យមកចោមវាយ ទ័ពថៅហ្វា កៅ, បើ ទ្រង់ អនុញ្ញាត ទូលបង្គំ យល់ឃើញ ថា មុខជានឹងឈ្នះ សត្រូវ ដោយងាយ។ ការទៅកេណ្ឌទ័ពបិសាចនេះ គឺទូលបង្គំ ត្រូវ បូជា ជីវិត ដោយលោតចូលក្នុង រណ្ដៅ ជម្រៅ ៨ ហត្ថ ៤ ជ្រុង ក្នុងនោះ មានដោត ចម្រឹង ឫស្សី មុតស្រួច។

ព្រះចន្ទរាជា ឮដូច្នេះ ទ្រង់ ក៏បដិសេធ បែបគ្មានជំនឿ ទាល់តែសោះ ក្នុងរឿងនេះ, តែ តាមឿង ក្រាបទូលបន្តថា៖ ‹‹បើ ទ្រង់មិនអនុញ្ញាត ទូលបង្គំនឹង អារ-ក ឱ្យស្លាប់នៅទីនេះ ក្នុងពេលឥឡូវនេះ ព្រោះ បើនឹងរស់នៅតទៅ ក៏មិនបានជួយយកអាសាផែនដី ថ្វាយព្រះអង្គដល់កម្រិតដែរ››។ និយាយ ចប់សព្វគ្រប់ហើយ តាមឿង ដកដាវនឹង អារ-ក តាមពាក្យខ្លួន បានក្រាបទូល។ ខណៈនោះ ព្រះចន្ទរាជា ទ្រង់ក្រឡេកឃើញទាន់ ក៏ស្ទុះទៅ

# អ្នកតាឃ្លាំងមឿង

ចាប់ងាវនោះ ចេញពីដៃ តាមឿង ហើយ ទ្រង់ មាន បន្ទូល ថា បើ ចៅពញា គិតថា រឿង ទៅ កេណ្ឌទ័ពបិសាច អាចធ្វើបាន ក៏ សូម ចៅពញា ធ្វើតាមគំនិតនោះចុះ។

មុននឹង តាមឿង បូជាជីវិត គាត់បានផ្តាំនឹង មេស្នឹងម្នាក់ ជា សំឡាញ់ ឈ្មោះ ចាន់ ថា៖ ឱ្យសម្លាញ់ឯង នៅជា មេស្នឹង ជំនួស អញ ដើម្បី និយាយ តពី ព្រះមហាក្សត្រ មកអញ កុំបីឱ្យព្រះអង្គ និយាយផ្ទាល់នឹងអញឡើយ, មួយទៀត បើដល់ថ្ងៃស្អែក ពេញបូណ៌មី ខែពិសាខ វេលាយប់ បើឯងឮសូរសន្ធឹកខ្ទរខ្ទារមេឃ ក្នុងដីហើយ ឱ្យឯង ក្រាបបង្គំ ទូល ព្រះបរមបពិត្រ សូមឱ្យ ទ័ពចេញ ពីបន្ទាយ វាយ ទ័ពសត្រូវ ជាប្រញាប់ចុះ អញ នឹងនាំទ័ពបិសាច មកជួយវាយ ជាប្រាកដ។

លុះបួងសួងហើយ តាមឿង ក៏លោតចូលក្នុងរណ្តៅ សម្លាប់ខ្លួន, ខណៈនោះ កូនប្រុស តាមឿង ទាំងបួន នាក់ ក៏មានចិត្ត បូជា ជីវិត ដើម្បី ទៅជួយបិតាខ្លួន នៅឋានបិសាច, ក៏នាំគ្នា រត់ទៅ លោតចូលក្នុងរណ្តៅ តែត្រូវបាន ខ្ញុំរាជការ ចាប់មិនឱ្យលោត តាម តែបានតែ ២នាក់ គឺ កូន ទី៣ និង ទី៤, ចំណែកឯ ចៅពញាវង្សាអគ្គរាជ កែវ និង ចៅពញាវិបុលបរទេស កែ វិញ ក៏ខ្ញុំរាជការ ចាប់មិនទាន់។

លុះដល់ ព្រះចន្ទចរត្រង់ ក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ (ខែ មេសា-ឧសភា) ក៏ស្រាប់តែឮសូរ សន្ធឹកខ្ទរខ្ទារមហិមា នៅលើមេឃ និង ក្នុងដី នាំឱ្យភិតភ័យ តក្កមាក្រៃលែង ហាក់បីដូច ជា

# អ្នកតាឃ្លាំងមឿង

កក្រើក ក្រឡាមហាប្រថពី, ខណៈនោះ មេស្នឹង ចាន់ យកសេចក្ដី ក្រាបបង្គំទូល ព្រះចន្ទរាជា តាមបន្ទាំ ខ្មោចតាមឿង គ្រប់ប្រការ, ស្ដេច ក៏ ប្រមូលទ័ព លើកចេញពីបន្ទាយ វាយសត្រូវ ជាបន្ទាន់។ ឯទ័ព សត្រូវ ឮសូរ សន្ទឹកខ្ទរខ្ទារ លើមេឃ និង ក្នុងដីផង សន្ទឹក ដូច ជា រន្ទះដូច្នោះ ក៏ភិតភ័យ ញ័រ ជើងដៃ រន្ធត់តក់ស្លុត រត់ចោលបន្ទាយ ចោលសស្ត្រាវុធ រត់គេចដោះខ្លួន ឱ្យរួចជីវិត តែសព្វខ្លួន។ ចៅហ្វា កៅ ក្រោយពី បែកទ័ព ដោយច្បាំងចាញ់ទ័ព ព្រះចន្ទរាជា និង ទ័ពបីសាច របស់ខ្មោច តាមឿង ក៏ដកទ័ព មកតាំងទី នៅខែត្រ ក្រគរ។ តែ សង្គ្រាម រវាងព្រះចន្ទរាជា និង ស្ដេចកន ក៏បន្ត អស់រយៈពេល ១០ ឆ្នាំ តែបន្តិចម្ដងៗ ព្រះចន្ទរាជា ក៏ចេះតែមាន ប្រៀបជាង ជានិច្ចរហូត ទទួលបាន ជ័យជំនះ ហើយ សម្លាប់ ស្ដេចកនបាន។

តាមជំនឿថា តាមឿង ស្លាប់ទៅ ក៏បន្តរស់ជា ព្រលឹង អ្នកតារក្សា ខែត្រ ពោធិសាត់ រហូត តទៅ។ រាល់ខែពិសាខ អ្នកស្រុកតែងតែ ធ្វើបុណ្យ ជូនដង្វាយ អ្នកតាឃ្លាំងមឿង ដើម្បី សូម សេចក្ដីសុខ និង ឱ្យមាន ក្សេមក្សាន្ត នៅក្នុងស្រុក តរហូតមកដល់សព្វថ្ងៃនេះ។

## អ្នកតាឃ្លាំងមឿង

# អត្ថធិប្បាយ ជា មតិផ្ទាល់ខ្លួន



យុវជនខ្មែរបុរាណម្នាក់

ដូចបានជំរាប ពីខាងលើរួចមកហើយ ថា ខ្មែរយើង ភាគច្រើន តែងតែ មានគំនិតថា តាមឿង ជួយ ព្រះចន្ទរាជា ច្បាំងនឹង សៀម ដើម្បី រំដោះ ស្រុកខ្មែរ។ ហើយ អ្នកខ្លះទៀត ទុក នរជន នោះ ជា វិរបុរសជាតិ ព្រោះ គាត់ ហ៊ាន បូជាជីវិត ដើម្បី ជួយ អាសាផែនដី។

ម្យ៉ាងមួយទៀត ជ័យជំនះ របស់ ព្រះចន្ទរាជា លើ ទ័ពសៀម ខ្មែរ យើងខ្លះ មិនរៃ តែងតែ ទុកជា ស្នាដៃ របស់ តាមឿង។ តើជា ការយល់ឃើញ សមហេតុផល ដែរឬទេ ? លើចំណុចនេះឯង ដែល យើងលើក យកមក ពិភាក្សាបញ្ហា ដើម្បីរក ការពិត ព្រោះការយល់នោះ វាអាចជា អញ្ញវាទកម្ម (détournement de la vérité)។

## ការបូជាជីវិត របស់ តាមឿង

ជាការពិត ការបូជាជីវិតខ្លួនឯង ដើម្បី បុព្វហេតុមួយ វា ទុកជា គុណសម្បត្តិ ខ្ពង់ខ្ពស់ណាស់ សំរាប់មនុស្ស។ តាមឿង

# អ្នកតាឃ្លាំងមឿង

ហ៊ានបូជាជីវិត ដើម្បី យក អាសា ចៅហ្វាយខ្លួន គឺ ព្រះចន្ទរាជា ដែល គាត់ទុក ជា សេចក្តីរុងរឿង នៃ ប្រជាជាតិខ្មែរ បើប្រៀប នឹង ស្តេចកន ដែល គាត់ទុក ជា រាជ្យភង្គ[2]។ ជម្រើស របស់ តាមឿង ជួយ ព្រះចន្ទរាជា គឺ នៅក្នុង គោលគំនិត ទុកខ្លួន ជាសេវិកជន (sujet) នៃ វង្សក្សត្រ ដែល ជា វង្ស ពេញសិទ្ធិ សំរាប់ គ្រងរាជសម្បត្តិ នៅ ក្រុងកម្ពុជា។ គោលគំនិតនោះ វា នៅក្នុង លំដាប់ នៃ គំនិត ផ្អែកលើ គោលការណ៍ ទ្វិភាគ (principe binaire) គឺ ‹អនុត្តរភាព - អនុកូលភាព› (domination-soumission )។ តាមឿង ជា រាស្ត្រ រស់នៅក្នុង សង្គម សក្តិភូមិ ដែល ជា សង្គម បញ្ឈរ ដូច្នេះ ឯង ចំណង នៃ សេចក្តីស្រឡាញ់ ស្តេច របស់គាត់ វា ជា សេរគតិ[3] ព្រោះ ព្រះមហាក្សត្រ ទ្រង់ ស្ថិត នៅពីលើ ជា ស្វេតច្ឆត្រ បង្កើត ជា ឆាយា នៃ សេចក្តីសុខ ក្សេមក្សាន្ត របស់រាស្ត្រ ដែល ជា មនុស្ស ស្ថិត នៅពីក្រោម។ នៅក្នុង ចិត្តគំនិត របស់ តាមឿង ការជួយ ព្រះចន្ទរាជា វា ជា សភាវគតិ មាន នៅក្នុង ជម្ពូជាតិ នៃ រាស្ត្រខ្មែរ ដូច្នេះ គាត់ មិនដែល នឹកគិត ម្តងណាឡើយ ថា ពលិកម្ម ដែល គាត់ បានធ្វើ ចំពោះ ចៅហ្វាយ ចិត្ត និង កាយ របស់គាត់ ជា អំពើ អជម្មជាតិ, ដូច្នេះ ការបូជាជីវិត របស់គាត់ គឺ ធ្វើ នៅក្នុង ការបន្ត តក្កសាស្ត្រ (une suite logique) នោះឯង។

---

2 រាជ្យភង្គ : អ្នកដណ្តើមរាជ្យ។
3 គតុសេរិ : ន. គតិ ជាសេរិក, អ្នកចំណុះ។

# អ្នកតាឃ្លាំងមឿង

## តើជារឿងពិត ដែរឬទេ ?

តែ យើង អាចសួរ ជា សំនួរ ថា ការបូជាជីវិត របស់ តាមឿង ទៅកេណ្ឌ ទ័ពបិសាច មកជួយច្បាំង ព្រះចន្ទរាជា តើ វា ជា រឿង ពិត ដែរឬទេ ?

រឿងនេះ វា អាច ជា យុទ្ធសាស្ត្រ នៃ ចិត្តសាស្ត្រ របស់ ព្រះចន្ទរាជា ប្រើ មរណភាព របស់ តាមឿង និង កូនប្រុស ២នាក់ របស់គាត់ ដើម្បី ការពារព្រះអង្គ ជា ប្រយោជន៍ ដល់ យុទ្ធសាស្ត្រសឹក។

នៅពេល ដែល ទ័ព ស្តេចកន ដឹកនាំ ដោយ ចៅពញាចក្រី លើក មកវាយ ទ័ព ព្រះចន្ទរាជា នៅពេលនោះ ព្រះចន្ទរាជា កំពុងតែ កទ័ព នៅឡើយ ដូច្នេះ ទ័ពនោះ មិនទាន់ត្រៀមខ្លួន ដើម្បី តទទឹងនឹង ទ័ព ស្តេចកន ដែល មាន ចំនួនច្រើនក្រៃ និង មាន នាយទ័ព និង នាយពល ជា អ្នក ខ្លាំងពូកែច្បាំង និង មាន ការពិសោធ ធ្វើសង្គ្រាមផង។ ទោះបីយ៉ាងណា តាមឿង ចេញច្បាំងនឹងសត្រូវ ដើម្បី ទុកពេលវេលា ឱ្យ ព្រះចន្ទរាជា កេណ្ឌទ័ព បន្ថែម និង រៀបចំ សាងបន្ទាយជ័យ ឱ្យបានមុតមាំ។ តាមឿង និង កូនប្រុស របស់គាត់ ២នាក់ ក៏លើកទ័ព ដោយនៅខ្វះ ការហ្វឹកហ្វឺនគ្រប់គ្រាន់ ទទួលច្បាំងនឹង ទ័ព របស់ ចៅពញាចក្រី នូវ ទោះបីដឹង ថា ចំនួន ទាហាន របស់ខ្លួន មានតិចតួចណាស់ និង គ្មានការពិសោធ នៅលើសមរភូមិ។ នៅពេល ច្បាំងនោះ ទ័ព កូន តាមឿង ត្រូវ បាន សត្រូវ រោមព័ទ្ធ ជាប់។ ហើយ ប្រហែល រងរបួស ជា ទម្ងន់ផង តែ នៅក្នុង

# អ្នកតាឃ្លាំងមឿង

ព្រះរាជពង្សាវតាខ្មែរ មិនបាន លើកយកមក និយាយ លើ ចំណុចនោះ ដើម្បី ទុក ប្រឌិតរឿង តាមឿង សម្លាប់ខ្លួន ដើម្បី ទៅ កេណ្ឌ ទ័ពបីសាច។ តាមឿង ដឹងថា កូន រងរបួស ហើយ សត្រូវ ព័ទ្ធជាប់ផង ក៏ស្រូតលើក ទ័ព ទៅជួយកូន ដោយ ប្រថុយជីវិត របស់គាត់។ ដូច្នេះឯង តាមឿង អាច រំដោះ កូន គាត់បានមែន តែ ខ្លួនគាត់ ក៏ប្រហែលជា រងរបួស ជា ទម្ងន់ នៅពេលនោះ។ នាយទ័ព របស់តាមឿង លាក់រឿងនេះ ទុក ជា រឿងសម្ងាត់សឹក ក៏នាំគ្នានាំ  តាមឿង និង កូន ២នាក់ ដែល រងរបួស ឬ ប្រហែល ជា ស្លាប់ ផង ស្រូត មក បន្ទាយ ព្រះចន្ទរាជា នៅ ខែត្រពោធិសាត់ តែម្ដង ដោយ បោះបង់ចោល បន្ទាយ ខែត្រក្រគរ។ មកដល់ ខែត្រពោធិសាត់ ព្រះចន្ទរាជា ក៏ បន្ត លាក់រឿងនោះ មិនឱ្យមហាជន និង រេហ៍ពល ដឹង ព្រោះ ជារឿង ដែល សត្រូវ អាចនឹងបោយ យកប្រយោជន៏បាន។ នៅ ពេលដឹងដំណឹង ថា ទ័ពសត្រូវ មាន បញ្ហាស្បៀងអាហារ ធូន់ធូរ ហើយ ប្រហែល ជា មាន ទាហាន ជាច្រើន លួចរត់ចោលជួរទ័ព និង បាក់ទឹកចិត្តនឹងបន្តធ្វើសង្គ្រាម, ព្រះចន្ទរាជា ក៏ប្រើ សង្គ្រាមចិត្តសាស្ត្រ ដោយ យក មរណភាព តាមឿង និង កូន ២ នាក់ ដែល ស្លាប់ដោយ របួស ជា ទម្ងន់ មក ប្រឌិតរឿង ពលិកម្ម ទៅកេណ្ឌទ័ពបីសាច នោះឯង។ ការប្រឌិត បែបនេះ គឺ ព្រះចន្ទរាជា ទ្រង់ ចង់ ឱ្យកេរ្តិ៍ឈ្មោះ តាមឿង ស្លាប់ ជា ការស្ម័គ្រចិត្ត ជួយយក អាសាព្រះអង្គ ពុំមែន ស្លាប់ ដោយ ច្បាំង ចាញ់ សង្គ្រាម សត្រូវ។ ត្រូវដឹងថា ការវាយសត្រូវ ដែល កំពុង មាន

# អ្នកតាឃ្លាំងមឿង

បញ្ហា អាហារ ពិបិន[4] និង ទុក្ខ ជាមុទ្ទជ:[5] គឺ ផ្ទើឡើង នៅពេល យប់ ហើយ មាន ភ្លៀង រន្ទះ យ៉ាងខ្លាំង ដែល ទ័ពសត្រូវ មិនគិតស្មានទាល់តែសោះ ថា ទ័ព ព្រះចន្ទរាជា ចេញវាយប្រហារខ្លួន នៅពេល អាកាសធាតុអាប់អួរ បែបនេះ។ រី រេហ៍ពល ព្រះចន្ទរាជា វិញ មាន ជំនឿ ថា បាតុភូត ជាធម្មជាតិនេះ គឺ ទ័ពបិសាច ដឹកនាំដោយ ខ្មោចតាមឿង មកជួយ ក៏កម្រើក ទឹកចិត្តក្លាហាន ចេញវាយខ្លាំង ប្រកបដោយ សក្តាតេជ (bravoure) រហូតវាយបែក បន្ទាយកិល[6] របស់ទ័ពសត្រូវ គ្រប់ជ្រុង។

បើឈរលើ របស់ពិត ដោយ មិនយក អបិយជំនឿ ជា មូលដ្ឋានគំនិត, ជ័យជំនះ ព្រះចន្ទរាជា នៅពេលនោះ គឺ ទុកជា ការប៉ិនប្រសប់ របស់ ព្រះអង្គ ជា អ្នកយុទ្ធសាស្ត្រ ដោយ ចេះប្រើ ផ្សំគ្នា អបិយជំនឿ, ឱកាស ជាអំណោយផល និង ការប៉ាន់ស្មានត្រូវ នៃ ការវិចវិល ទឹកចិត្ត តស៊ូ របស់ សត្រូវ។ គួរគិតថា តាមឿង កាលនៅរស់ គាត់ មិនមែន ជា មេទ័ព ប៉ិនប្រសប់ ខាង យុទ្ធសាស្ត្រសង្គ្រាម នោះទេ គាត់ គ្រាន់ តែ ជា មេស្នឹង ភ្នំក្រវាញម្នាក់ ល្បីល្បាញ ហើយ មាន ទឹកចិត្ត ស្មោះត្រង់ ចំពោះ ព្រះចន្ទរាជា ដោយជួយ ព្រះអង្គ គ្មាន ចិត្តក្រហែង, តែ ជំនួយ របស់គាត់ វា មានកម្រិត នៅក្នុង មហាសង្គ្រាម, ប្រហែលជាដូច្នេះឯង បាន ជា មាន រឿងប្រឌិត ថា ប្រយោជន៍ របស់ តាមឿង ចំពោះ ព្រះ

---

[4] ពិបិន : ពិបាកក្រៃ។
[5] មុទ្ទជ: : មានកើតឡើងនៅក្នុងក្បាល។
[6] បន្ទាយកិល : បន្ទាយ ដែលអាចរំកិលបាន។

## អ្នកតាឃ្លាំងមឿង

ចន្ទរាជា វា មាន នៅក្នុង ពិភពបីសាច ជាង នៅក្នុង ពិភព នៃ មនុស្សលោក។ លុះចំណេរមក វា កើត អបិយជំនឿ ថា ខ្មោចតាមឿង ទៅកើត ជា អ្នកតា ឃ្លាំងមឿង ជា អ្នកតា រក្សាស្រុក ពោធិសាត់ ហើយ ក៏ភ្ជាប់ ប្រវត្តិ តាមឿង ថា ជា អ្នក ជួយយក អាសា ព្រះចន្ទរាជា ទាល់តែ ច្បាំងឈ្នះសត្រូវ ដោយ មិនបាន ដឹងច្បាស់ ឬ មិនរវល់ចង់ដឹង ការពិត ថា សត្រូវ នៅពេល ដែល តាមឿង ជួយ ព្រះចន្ទរាជា មិនមែន ជាទ័ពសៀម គឺ ទ័ព ស្តេចកន ឯណោះទេ។ របប រាជានិយម អាចចាត់ទុក ខ្មោចតាមឿង ជា វិរបុរស ព្រោះ គាត់ បានជួយ ស្តេច ច្បាំងនឹង រាស្ត្រ ជា អ្នកដណ្តើមរាជ្យ ហើយ ស្តេច ទទួល បានជ័យជំនះ, តែ គេអាច នឹងទុក វិរភាព របស់ តាមឿង មាន កម្រិត នៅក្នុង ក្របខណ្ឌ អ្នកឈ្នះ តែគ្មាន ទំហំជាតិនោះឡើយ ហើយ ស្តេចកន ក៏មាន ខ្មែរ មួយភាគ ទទួល ស្គាល់គាត់ ជា វរជន ឬ អ្នកបដិវត្តិ ដ៏សំខាន់មួយ នៅក្នុង ប្រវត្តិសាស្ត្រជាតិ។ ដូច្នេះ តាមឿង ជា វិរបុរស និង ស្តេចកន ជា វរជន វា ជា សម្មានការ តាម អ្នកចូលចិត្ត (considération partisane), ម្ខាង ចោទ ម្ខាងទៀត ថា ជា មុសាវាទី[7] ព្រោះ ម្ខាងៗ មាន មុទិតាចិត្ត[8] ជ្រុល ទៅលើ វិរបុរស របស់ខ្លួន។ តែ ការពិត អ្នកទាំងសងខាង ភ្លេចគិត ថា សង្គ្រាម រវាង ទ័ព តាមឿង នឹង ស្តេចកន ជា សង្គ្រាម រវាង ខ្មែរ នឹង ខ្មែរ នាំឱ្យ រាស្ត្រប្រជា ទទួល រងទុក្ខវេទនា ព្រោះ តែ ព្រះចន្ទរាជា ចង់ សង

---

7 មុសាវាទី :អ្នកដែលនិយាយកុហក។
8 មុទិតា : សាមានចិត្ត។

# អ្នកតាឃ្លាំងមឿង

សឹក និង ប្រាថ្នា រាជបល្ល័ង្ក ដោយ យក សង្គ្រាម ធ្វើជា មធ្យោបាយ ដាច់ខាត។ ដូច ស្តេចកន វាយប្រហារ ព្រះស្រី សុគន្ធបទ ដើម្បី សងសឹកនឹង ស្តេចនោះ ដែល មាន បំណង ចង់ សម្លាប់ខ្លួន គ្មានហេតុផល។ រី តាមឿង វិញ ចូលរួម ចំណែក ធ្វើ សង្គ្រាម ស៊ីវិល ដែល នៅក្នុង សង្គ្រាមនោះ មានតែ ខ្មែរ ជា អ្នករងគ្រោះ គ្រប់ប្រការ, ដូច្នេះ គេ អាចសួរបាន ថា តើ វិរភាព របស់គាត់ នៅត្រង់ណា ?

## តើ ហេតុអ្វីបានជា តាមឿង មិនជួយ ព្រះស្រីសុគន្ធបទ ?

គេ អាច ឆ្ងល់ បានដែរ ថា ហេតុអ្វី ក៏ តាមឿង មិន កៀងគរ ព្រះចន្ទរាជា ឱ្យកទ័ព ជួយ ព្រះស្រីសុគន្ធបទ ហើយ បណ្តោយ ឱ្យ ព្រះអង្គ ភៀសខ្លួន ទៅ ស្រុកសៀម ? ចុះ បើ ព្រះចន្ទរាជា កុហក តាមឿង ថា ទ្រង់ ទៅ ស្រុកសៀម ដើម្បី សូមជំនួយ ពី ព្រះចៅ សៀម ហើយ វិលត្រឡប់ មកច្បាំង ជួយ ព្រះរាម វិញ, តើ វា អាច មាន សាច់រឿង (scénario) បែបនេះបាន ដែរឬទេ ? នៅពេល ដែល ព្រះស្រីសុគន្ធបទ ច្បាំងនឹង ស្តេចកន, តាមឿង គ្មាន គិតរវល់ រក មធ្យោបាយ ជួយ ព្រះរាជា ព្រោះ គាត់ ដឹងខ្លួន ថា គាត់ គ្រាន់តែ ជា មេស្នឹងម្នាក់ គ្មាន ប្រជាប្រិយភាព អាច ប្រមូល រាស្ត្រប្រជា បង្កើត ជា ក្រុមយោធា តូចធំក្តី ឬ ប្រមូល ស្ម័គ្របក្ស ពួក និង កូន ទាំងបួន ចូលខ្លួន សូមបំរើ ព្រះរាជា បាននោះ ឡើយ។ តែ បើ យក ជំនឿ ថា ខ្លួន អាច ទៅកេណ្ឌ ទ័ពបិសាច ក៏ច្បាស់ ជា ពួកមហាមន្ត្រី សេនាសេនីយ៍ ណាម្នាក់ គេជឿខ្លួន

# អ្នកតាឃ្លាំងមឿង

នោះដែរ ព្រោះ វណ្ណៈ អ្នកដឹកនាំ គេ មាន ព្រាហ្មណ៍បុរោហិត និង ពិជ័យហោរា នៅក្នុង ព្រះបរមរាជវាំង ជា មគ្គុទេស នៃ ជំនឿ។ ដូច្នេះ តាមឿង ក៏មិនមែន ជា អ្នករាជានិយម ផ្ដាច់ឬស (royaliste radicale) នោះដែរ។ ជំនួប ជាមួយ ព្រះចន្ទរាជា ជា ចៃដន្យ ដែល ព្រះចន្ទរាជា ចេះឆ្លៀត ទាញយក ប្រយោជន៍ បាន ពី តាមឿង តែប៉ុណ្ណោះ ព្រោះ ព្រះអង្គ នៅពេលនោះ ជា ស្ដេច ឯការ និង មាន បាទដៃទទេ, ដូច្នេះ ជំនួយ របស់ តាមឿង ទោះបីតិចតួច ក្ដី វា ជា សន្និធិ[9] ចំពោះ អ្នកខ្សត់, វីរកម្ម របស់ តាមឿង វិញ ទុក ជា ឥន្ទ្រីយ[10] នៅក្នុង បរិបទ បែបនេះ។ ចំណែក ព្រះស្រីសុគន្ធបទ ព្រះអង្គ គ្មាន ខ្វះអ្វីនោះឡើយ ដូច្នេះ អ្វី ដែល ព្រះអង្គ ត្រូវការ ពី ប្រជារាស្ត្រ ឬ អ្នកដទៃ គឺ មានតែ នៅក្នុង គោលការណ៍ នៃ ‹‹អនុត្តរភាព - អនុកូលភាព›› ដែល ផ្ទុយ ពី ស្ដេចកន និង ព្រះចន្ទរាជា ដែល ជា អ្នកប៉ិនប្រសប់ ស្វែងរក ផលប្រយោជន៍ នៅ គ្រប់ ឱកាស ដែល ហុចឱ្យ និង នៅគ្រប់ មជ្ឈដ្ឋាន ដោយ ប្រើ គោលការណ៍ នៃ ‹‹ អនុកូលភាព ជា មិត្តភាព ›› ដោយ ទុក ខ្ញុំបំរើ ជា មនុស្ស សំខាន់ នៅក្នុង គំរោង របស់ខ្លួន ហើយ ចេះផ្ទៃ ការបំរើនោះ ជា សកម្ម។ តែ រឿង នោះ ក៏អាចទុកជា កត្តា នៃ ភ័ព្វសំណាង នោះដែរ ដែល ជា កត្តាមួយ សំខាន់ណាស់ដែរ នៅក្នុង ជីវិត នៃ មនុស្សលោក ក៏ ដូចជា កត្តា នៃ សុភនិច្ឆ័យ (bon sens) ដែល មាន វិធានផែនការ

---

[9] សន្និធិ : ន. ការសន្សំទុក, ការសំចៃទុក។
[10] ឥន្ទ្រីយ : សទ្ធា ដែលជារាប់ថាជាធំមួយ របស់ សត្វលោក។

## អ្នកតាឃ្លាំងមឿង

ត្រឹមត្រូវ ជា ពន្លឺ បំភ្លឺផ្លូវ។ មាន គំនិតល្អ តែ មិនដឹង ថា ត្រូវ ធ្វើបែបណា គឺ ជា សត្រូវមួយ សំរាប់ខ្លួន។ តាមឿង និង ព្រះស្រី សុគន្ធបទ, ម្នាក់ៗ ដើរ លើផ្លូវ ពីរស្របគ្នា តែមិនជួបគ្នា, តើ អាច ទុកជា សំណាងអាក្រក់ របស់ ព្រះស្រីសុគន្ធបទ ? ចម្លើយ គឺ ថា ទេ ព្រោះ ព្រះអង្គ មាន យុនហ្លួងព្រះស្ដេចកន ជា អ្នកបំរើ ជា អ្នកចេះដឹង តែ ព្រះអង្គ បែរ ទុកជា សត្រូវ ទៅវិញ ដែលនាំ ឱ្យខាតប្រយោជន៍ ដល់ ព្រះអង្គ។ ចំណែក តាមឿង បើ យោង តាម បរិបទនៃ ការឧបត្ថម្ភ របស់ តាមឿង វា មាន លក្ខណៈ ជា កាលវត្តនិយម ដូច្នេះ គេ អាចទុក តាមឿង ជា មនុស្សឱកាស និយម ក៏បានដែរ។ គាត់ ជួយ ព្រះចន្ទរាជា ព្រោះ គាត់ មាន ជំនួប ជាមួយ ស្ដេចនោះ ដោយ ចៃដន្យ, តែ គាត់ មិនបាន ប្រឹងប្រែង ស្វែងរកជួប ព្រះស្រីសុគន្ធបទ ដើម្បី ជួយ ព្រះមហា ក្សត្រ ក្នុង ចរិត ជា អ្នករាជានិយម ប្ដូរផ្ដាច់ នោះឡើយ។

## សង្ខេប ប្រវត្តិសាស្ត្រ

ការលើក ផែនដី ព្រះបាទ ពញាយ៉ាត (១៣៨៤-១៤២៧) នៅ ក្នុង សតវត្ស ទី១៤ និង ទី១៥ មក សង្ខេប គឺ ទុកជា កញ្ចក់ សំ រាប់ ឆ្លុះមើល ដើម្បី យល់ដឹង អំពី ស្ថានភាព នយោបាយ សំខា ន់ៗ នៅ ស្រុកខ្មែរ ដែល ជា យុគ ថ្មី នៃ របប ដឹកនាំជាតិ ផ្ដាច់ ពី សម័យ អង្គរ។ ព្រះបាទ ពញាយ៉ាត ជា និមិត្តរូប នៃ មហា ក្សត្រដៃ ព្រោះ ជា អ្នក រំដោះជាតិ ពី ការត្រួតត្រាសៀម តែ ព្រះ អង្គ ក៏ជា ក្សត្រ បង្កើត សន្តរាជវង្សខ្មែរថ្មី បោះបង់ មហា

នគរ មកតាំង ព្រះរាជវាំងថ្មី នៅក្នុង ខេត្ត ស្រីសន្ធរ[11] ក្នុង ឆ្នាំ ១៣៩២។ ការផ្ទេរ រាជធានី នេះ ជា យុទ្ធសាស្រ្ត យោធា ផង ជា និមិត្តរូបសំខាន់ នៃ ការផ្តាច់ពី សន្តរាជវង្ស អង្គរ ផង។

ទី១. ជា យុទ្ធសាស្រ្ត យោធា ព្រោះ មហានគរ ស្ថិត នៅ ក្បែរព្រំប្រទល់ ខ្មែរ-សៀម ព្រោះ ខែត្រខ្មែរ ជា ច្រើន នៅ ទិសខាងកើត នៅ ក្បែរ មហានគរ បាន ធ្លាក់ ក្នុង ការកាន់កាប់ សៀម ដូច្នេះ សៀម ងាយ ស្រួល វាយ ចូល មហានគរណាស់ ហេតុនេះឯងហើយ បានជា ព្រះបាទ ពញាយ៉ាត ទ្រង់ ផ្ទេរ រាជធានីដោយ យក «ចម្ងាយ និង រយះពេល» ធ្វើ ជា ការការពារ ជា ធម្មជាតិ រាជធានី : យុទ្ធសាស្រ្តនេះ ឈរលើ ចម្ងាយ គឺ តម្រូវ អោយ ខ្មាំង ប្រើ ពេល វេលាយូរ លើក ទ័ពមក វាយ រាជធានី ហើយ នៅ ពេលនោះ វា អាច អោយ ព្រះអង្គ មាន លទ្ធភាព កែន កងទ័ព ឱ្យបាន ទាន់ពេលវេលា ដើម្បី ទប់ទល់នឹង ខ្មាំង។ តែ យុទ្ធសាស្រ្តនេះ វា ផ្អែក តែទៅលើ ការការពារ សុទ្ធសាធ ដែល បើក ឱកាស អោយ ខ្មាំង យក ទឹកដីជាតិ ធ្វើជា សមរភូមិ នាំបង្កើតអសន្តិសុខ រំខាន ឬ បំផ្លាញ សេដ្ឋកិច្ចជាតិ ដែលជា ដង្ហើម នៃ ប្រជាជាតិ និង អាយុជីវិត របស់ កងទ័ព ដូចសុភាសិតខ្មែរ បាន ថ្លែង ថា «ធ្វើ ស្រែ នឹងទឹក ធ្វើ សឹកនឹងបាយ»។ ចំណុច មួយទៀត គឺ នៅ ត្រង់ ថា ជ័យជំនះ ព្រះបាទ ពញាយ៉ាត លើ សៀម គឺ ឈ្នះ ត្រឹមតែលើ កងទ័ពសៀម ដែល មក តាំងទី នៅ ក្នុង មហានគរ តែប៉ុណ្ណោះ ហើយ រំដោះ បាន រាជធានីខ្មែរ តែ មិនមែន ជា ជ័យជំនះ លើ ប្រទេសសៀម នោះ

[11] ខេត្ត ស្រីសន្ធរ ដើមឡើយឈ្មោះខេត្ត បាសាន។ (ស្រីសន្ធរ ជាពាក្យ យារពី ស្រីសឈរ)។

ឡើយ ជា ពិសេស ខែត្រខ្មែរ ទាំងឡាយ ដែល សៀម វាយ យក បានរួចទៅហើយ, ព្រះបាទពញាយ៉ាត មិនមាន លទ្ធភាព រំដោះ បានវិញ នោះទេ។ ហេតុនេះឯង បានជា ព្រះបាទពញាយ៉ាត មាន ការបារម្ភ ជានិច្ច នៃ ការសងសឹង ពី ព្រះចៅសៀមមក លើ រូប ព្រះអង្គ ដែល ជា អ្នកទទួលខុសត្រូវ លើ មរណភាព ក្នុង សង្គ្រាម របស់ រាជបុត្រសៀម ដែល ព្រះអង្គ ទុកឱ្យ នៅ គ្រង ក្រុងកម្ពុជា។

ទី២. ជា ការកាត់ផ្តាច់ ពី សន្តរាជវង្ស អង្គរ ព្រោះ រាជវង្សនេះ លែង មាន រូបភាព ជា រាជវង្ស ឧត្តុងឧត្តម សំរាប់ជាតិខ្មែរ ទៀតហើយ ព្រោះ ជា សន្តរាជវង្ស កាន់ ព្រហ្មញ្ញសាសនា ដែល មិនមែនជាសាសនា របស់ប្រជារាស្ត្រខ្មែរ។ ការប្តូរសាសនា មាន តាំងពី រាជ្យ ព្រះបាទ តាត្រសក់ផ្អែម មកម្លេះ។ នៅក្នុង សម័យ នោះ មាន កើត បដិវត្តន៍ នៅ ក្នុង វណ្ណៈ អ្នកដឹកនាំ រហូត ធ្វើ ឃាត ព្រះមហាក្សត្រ ចុងក្រោយបង្អស់ នៃ សន្តរាជវង្ស អង្គរ ព្រះនាមព្រះបាទ សេណករាជ ដើម្បី លើក ពុទ្ធសាសនា ជា សាសនាជាតិ ឱ្យ ស្របនឹង ចំណុច ចិត្ត ប្រជារាស្ត្រ ដែល ជា អ្នក កាន់ ពុទ្ធសាសនា។ តាត្រសក់ផ្អែម[12] ត្រូវ បាន នាម៉ឺនមន្ត្រីព្រះ រាជវាំង លើក តាំងជា មហាក្សត្រខ្មែរ ព្រោះ គាត់ ជាមនុស្ស មាន សេចក្តីក្លាហាន ហ៊ានដឹកនាំ ការប្រហារ ព្រះមហាក្សត្រ។ ពួក ទាំងនោះ នាំ គ្នា ច្នៃ ឃាតកម្ម នោះ ជា អំពើ អចេតនា ទុក ជា កម្មផល របស់ ព្រះបាទ សេណករាជ។ រីឃាតករ វិញ ត្រូវ បាន ទទួលផលកុសល ព្រោះខ្លួន បានបំពេញ ករណីយកិច្ច របស់ ខ្លួន តាម រាជបញ្ជា; ម្យ៉ាងមួយ ទៀត តាត្រសក់ផ្អែម ជា

[12] ព្រះនាមជាព្រះមហាក្សត្រ គឺ ព្រះរាជឱង្ការ ព្រះបរមរាជាធិរាជ ជ័យ។

# អ្នកតាឃ្លាំងមឿង

អ្នកកាន់ពុទ្ធសាសនា បរិសុទ្ធ នឹងធម៌ មាន ប្រជ្ញា ភ្លឺថ្លា មោះមុត ជា អ្នកនិព័ន្ធ រឿងល្ខោន ប្រកប ដោយ គុណភាព គួរមើល កំសាន្ត ព្រោះជា ទស្សនីយភាព ដ៏ អស្ចារ្យ។ ត្រង់ ចំណុចនេះ គេ សួរ ជាសំណួរ បានថា តើ តាត្រសក់ផ្អែម អាច ជា អ្នកដឹកនាំរឿងល្ខោន ពិឃាត ព្រះបាទ សេណករាជ បានដែរឬទេ ? ចម្លើយ អាចឆ្លើយ ថា បាន។ បើ លើកយក ឃាតកម្ម សុក្រឹតនេះ មក ពិចារណា បន្តិច វាមានរូបភាពដូចជា រឿងល្ខោនដែលគេ រៀបចំឡើង។

ទី៣. ចំពោះ អ្នកស្រាវជ្រាវបរទេស គេ យល់ ឃើញថា វិបត្តិ វារី ជា កត្តា ចម្បង ដែល នាំឱ្យ ព្រះបាទ ពញាយ៉ាត បោះបង់មហានគរ ព្រោះ វិបត្តិ នោះ នាំ បង្កើត ដល់បញ្ហា សេដ្ឋកិច្ច សំរាប់ ចិញ្ចឹម ជីវិត។ ប្រជាជន រស់ នៅក្នុង មហានគរ ជួបប្រទះនឹង វិបត្តិ របប ចិញ្ចឹមជីវិត កើតមក ពី កង្វះ ទឹក ប្រឡាយទឹក បង្ហូរទឹក ពីទន្លេសាបមក បំពេញ បារាយទឹក សំរាប់ ធ្វើស្រែ និង សេចក្តីត្រូវការ សំរាប់ ការរស់នៅ ជា ធម្មតា របស់ប្រជាជន ព្រោះ ប្រឡាយទាំងនោះ គ្មាន ការថែរក្សា ឲ បានជិតដល់។ រឿង នេះ វា មាន ហេតុផល ជា ច្រើន ជា អាថ៌ គឺខ្វះ ធនធាន មនុស្ស ព្រោះ សង្គ្រាម ជំរុញឱ្យ ប្រជាជន រត់ភៀសខ្លួន ចេញ ពី ដំបន់ មហានគរ ព្រោះ ខ្លាចអាថ្វាធរ កេណ្ឌធ្វើ ទាហ៊ាន និង ខ្លាច សៀម ចាប់ បញ្ជូនទៅ ស្រុកគេ ចោលស្រុកឯង។

# អ្នកតាឃ្លាំងមឿង

## សង្ខេបជីវប្រវត្តិ ព្រះបាទ ពញាយ៉ាត



ព្រះរាជបុត្រមួយព្រះអង្គ

ព្រះបាទ ពញាយ៉ាត មាន ព្រះរាជបុត្រា និង បុត្រី ជាច្រើន តែ បុត្រា ៣អង្គ ដែលមាន ស្នាម ព្រះនាម នៅក្នុង ប្រវត្តិសាស្ត្រ គឺ : ព្រះនរាយណ៍រាជា (មាតា មាន នាម អ្នកម្នាង ទេវី) ព្រះសេរីរាជា (មាតា មាន នាម អ្នកម្នាង បទុមកេសរ) ព្រះធម្មរាជា (មាតា មាននាម ព្រះម្នាង ស៊ី សាងាម ជា សៀម) ជា ស្នំឯក។ ព្រះម្នាង ស៊ី សាងាម ជា អតិត ព្រះម្នាង របស់ព្រះឥន្ទរាជា (១៣៨០) ដែលជា កូន ស្តេចសៀម ព្រះនាម ព្រះបរមរាជា។ ព្រះឥន្ទរាជា ជា រាជបុត្រ ទី៣ ដែល ព្រះចៅសៀម ទុក ឱ្យ នៅ ត្រួតត្រា ក្រុងកម្ពុជា ក្នុង ឋានៈ ជា មហាក្សត្រខ្មែរ។ ក្រោយ ពេលដែល ព្រះអង្គ ច្បាំងចាញ់ ព្រះបាទពញាយ៉ាត ហើយ ទទួល មរណៈ ក្នុងសង្គ្រាម នៅក្នុង មហានគរខ្មែរ, ព្រះពញាយ៉ាត ក៏ សព្វ ព្រះទ័យនឹង ព្រះម្នាង ស៊ី សាងាម នោះណាស់ ព្រោះ មាន

# អ្នកតាឃ្លាំងមឿង

រូប ឆោម លោមពណ៌ យ៉ាងល្អ។ ទ្រង់លើក តាំង ជា ស្នំឯក មាន ឋានៈ ជា ព្រះម្នាង ដដែល។



កំណាព្យស្នេហ៍ (បទមេបួន)

សរសេរដោយ ឧប សៅ សង្ហា

*ឃើញឯងបាត់នឿយ  រូបឆោមល្អម្លេះ*
*នាំចិត្តឲចេះ  ស្នេហ៍ឆោមបុប្ផា។*
*អញជាម្ចាស់ថ្មី ក្រុងកម្ពុជា*
*សេរីមានងារ ជាស្រុកឯករាជ្យ។*
*ពញាយ៉ាតដៃ ក្សត្រឈ្នះសង្គ្រាម*
*ចិត្តជាទាហាន សូមស្នេហ៍កេសី។*
*អញច្បាំងហត់កាយ តែមានរាសី*
*ជួបឯងជាស្រី ឆោមលោមពណ៌ល្អ។*

# អ្នកតាឃ្លាំងមឿង

ព្រះរាជបុត្រព្រះម្នាង ស៊ី សាងាម, ព្រះបាទធម្មរាជា នេះឯង ជាអ្នកឈ្នះសង្គ្រាម លើព្រះរាម និង ព្រះភាគិនេយ្យា (ក្មួយ)[13] របស់ព្រះអង្គ ទាំង ពីរព្រះអង្គ ដោយសារ ព្រះអង្គ ទៅពឹង ស្តេចសៀម ក្នុង នាម ព្រះអង្គ ជាកូនកាត់ ខ្មែរ-សៀម ឱ្យ មកធ្វើអន្តរាគមន៍ ជួយព្រះអង្គ ហើយ ប្រើ ល្បិចកល បោក បញ្ឆោតព្រះរាម និង ព្រះភាគិនេយ្យា ឱ្យ ស្តេចសៀម ចាប់ យក ទៅស្រុកសៀម ហើយ ទទួល ស្គាល់ ព្រះអង្គ ជា មហាក្សត្រខ្មែរ។

ព្រះបាទ ធម្មរាជា មាន ព្រះរាជបុត្រា ពីរ ព្រះអង្គៈ ព្រះស្រីសុគន្ធបទ ជា ព្រះរាជបុត្រា ច្បង និង ពញាចន្ទរាជា[14] ជា អនុជ។

រឿង ស្តេចកន មាន កើតឡើង ក្នុងរាជ ព្រះបាទ ស្រីសុគន្ធបទ (១៥០៤-១៥១២) ដែល ខ្ញុំ លើកយកមក វិភាគ ក្នុង គំនិតថ្មី ដើម្បី ពិចារណា អំពី ស្ថានភាពសង្គម និង នយោបាយខ្មែរ នៅ ក្នុង សតវត្ស ទី១៦។

មាន អ្នកប្រវត្តិសាស្ត្រ ខ្លះ គេ រាប់ បញ្ចូល ការរកឃើញ ទ្វីប អាមេរិក (១៤៩២) ដោយ លោក Christophe Colombe ជា ការចាប់ផ្តើម នៃ សតវត្ស ទី១៦។ នៅ អឺរ៉ុបគេ ទុក សតវត្ស ទី១៦ ជា សតវត្ស «បញ្ញាថ្មី» និង «សិល្បៈថ្មី» ជា សតវត្ស ដែល អ្នក

---

13 ព្រះស្រីសុរិយោទ័យ ត្រូវជាព្រះបុត្រព្រះនរាយណ៍រាជា។ ពេលដែលព្រះបិតា សុគតទៅ ព្រះរាជវង្សានុវង្ស និង នាម៉ឺន សព្វមុខមន្ត្រី នាំគ្នា អញ្ជើញ ព្រះសេរីរាជា ជា ព្រះអនុជ បន្ទាប់ ឲឡើង សោយរាជ្យស្នងព្រះបិតា របស់ព្រះអង្គ ដែលនាំអោយ ព្រះអង្គ អាក់អន់ព្រះហទ័យហើយ រង់ចាំឱកាស ជានិច្ច នឹងដណ្តើមរាជ្យ ពី ព្រះសេរីរាជា។ នៅក្នុង សម័យនោះ ស្រុកខ្មែរ មានមហាក្សត្របី ច្បាំងគ្នា ដណ្តើមងារ ជា មហាក្សត្រស្របច្បាប់ក្រុងកម្ពុជា អស់រយៈពេលជាងដប់ឆ្នាំ។

14 ពញា ចន្ទរាជា កើតចំនៅពេលចន្ទ្រគ្រាស ដូច្នេះក្រុមបារគូ បុរោហិតហោរាចារ្យ នាំគ្នា ថ្វាយ ព្រះនាម ថា ព្រះចន្ទរាជា។

# អ្នកតាឃ្លាំងមឿង

ប្រាជ្ញ រកឃើញ ចំណេះធំៗ ជាច្រើន សំរាប់ មនុស្សជាតិ។ នៅស្រុកខ្មែរ វិញ សតវត្ស ទី១៦ ចាប់ ផ្តើម ពី រាជ្យ ព្រះបាទសុគន្ធបទ ហើយ បញ្ចប់នៅ ផ្តើម រាជ្យ ពញា អន (១៥៩៩) បន្ត ពី រាជ្យ ព្រះរាមជើងព្រៃ (១៥៩៣) ដែល ជា ស្តេច ឡើង គ្រងរាជ្យបន្ទាប់ ភ្លាម ពី សៀម វាយ បែក បន្ទាយ លង្វែក។ ត្រូវ ដឹងថា សៀម វាយ បែក បន្ទាយ លង្វែក មែនពិត តែ មិនមានជ័យជំនះ លើ កងទ័ពខ្មែរ ទាំងអស់ នោះទេ។ ព្រះរាមជើងព្រៃដែល ជា ញាតិវង្ស ជា មេទ័ពខ្មែរ ល្បីម្នាក់, ទ្រង់បាន កេណ្ឌទ័ពច្បាំងនឹង សៀម វិញ ភ្លាម ដើម្បី តាមដណ្តើម យក មក វិញ នូវបេតិកភ័ណ្ឌជាតិខ្មែរ ដែលសៀម ប្រមូល យក ពីបន្ទាយលង្វែកនិង រំដោះ ប្រជារាស្ត្រខ្មែរ ដែល ព្រះចៅសៀម ព្រះនាម ព្រះនរេន្ទ្រសួរ កៀរតាំង ពី ក្រោយ ទាំង សងខាង ពី ខែត្រ សំរោងទោង លង្វែក ទៅ ដល់ ខែត្រ នាងរង ប្រមាណ ១២ សែននាក់នាំ យក ទៅ ស្រុកសៀម។ តែ គោល បំណង របស់ ព្រះរាមជើងព្រៃ នេះ មិនបាន ទទួល ជោគជ័យទេ ព្រោះ ទ័ពសៀមដកថយ ទៅស្រុកគេវិញបាន យ៉ាងរហ័ស ទាន់ពេលវេលា។ តែ ព្រះរាមជើងព្រៃ បាន ច្បាំង រំលាយកងទ័ព ត្រួតត្រារបស់សៀម តាំងនៅ ស្រុកឧដុង្គបែក រត់ ត្រឡប់ ទៅស្រុកវិញបានតិចតួចបំផុត។ តែ បីឆ្នាំ ក្រោយមក ព្រះរាមជើងព្រៃ ត្រូវ បានជនជាតិ ព័រទុយហ្គេស៏ម្នាក់ ឈ្មោះ ល្វីវ៉េឡូហ្សូ និងសេនា ២៤ នាក់ ធ្វើ ឃាត ព្រះអង្គ បាន នៅ ក្នុង ព្រះបរមរាជវាំង ដោយប្រើ ល្បិចកល។ ជនបរទេសនោះ ជា មិត្តនឹង ព្រះបាទជ័យជេដ្ឋា ជា មហាក្សត្រខ្មែរដែល បាន លួច រត់គេចខ្លួន ពី បន្ទាយលង្វែក នៅពេល កំពុង មាន សង្គ្រាម។ ក្រោយ ពី សម្លាប់ ព្រះរាមជើងព្រៃ បានហើយ ជនបរទេស នោះ បាន ទៅអញ្ជើញ

ពញា តន់ ដែល ជា បុត្រ កណ្ដាល របស់ ព្រះបាទជ័យជេដ្ឋា ពី ខែត្រ ស្ទឹងត្រែង ឱ្យ មក សោយរាជ្យ តពី ព្រះបិតា ក្នុង ស្រុកស្រី សន្ធរ។ ក្រោយ មក ពញា តន់ ត្រូវបានពួក ចាម លួច ធ្វើ ឃាត ដោយ ប្រើ ល្បិចកល។ ព្រះមហាទេវីក្សត្រី ដែល ត្រូវ ជា ព្រះមាតុច្ឆា ពញា តន់ ក៏ យាងអញ្ជើញ ពញា អន ដែល ជា បុត្រា នៃ សម្ដេច ព្រះបរមចន្ទរាជា មួយ អង្គ ដែរ ឱ្យឡើង គ្រង រាជសម្បត្តិ នៅ ក្រុងកម្ពុជា គឺ ជា រាជ្យ បញ្ចប់ សតវត្ស ទី ១៦ នោះឯង។

## ព្រះស្រីសុគន្ធបទ

ក្នុង ជន្មាយុ ២៦ ព្រះវស្សា ព្រះស្រីសុគន្ធបទ ជា ព្រះរាជបុត្រ ច្បង នៃ ព្រះធម្មរាជា ទ្រង់ បានឡើង សោយរាជ្យ ស្នង ព្រះបិតា ក្នុង គ.ស. ១៥០៤ នៅ ចតុម្មុខ ស្រុកភ្នំពេញ។

សោយរាជ្យ បាន ៤ ឆ្នាំ ព្រះអង្គ មាន ព្រះរាជតម្រិះ ចង់ ប្ដូរ រាជ ធានី ពី ស្រុកភ្នំពេញ មក នៅ ស្រុកបាសាន (ស្រីសន្ធរ) ដែល ជា អតិត រាជធានី របស់ព្រះអយ្យកោ (ជីតា) ព្រះបាទ ពញាយ៉ាត។ ទន្នីករណ៍ របស់ ព្រះអង្គ គឺ យុទ្ធសាស្ត្រសង្គ្រាម។

នៅក្នុង អង្គប្រជុំ រាជគណ រដ្ឋមន្ត្រី ពិសេស ព្រះរាជា មានព្រះ បន្ទូល ទៅ កាន់ អង្គប្រជុំ ថា ៖

- ស្រុក ស្រីសន្ធរ ជា ទីកន្លែង ល្អ ប្រពៃ សំរាប់ តាំង ជា រាជធានី ព្រោះ មាន មធ្យោបាយ ជា ធម្មជាតិ សំរាប់ការពារបន្ទាយរាជ្យ ត្បិត មាន បឹង ខណ្ឌ ខាងជើង មានទន្លេ ខណ្ឌ ខាងកើត មាន

# អ្នកតាឃ្លាំងមឿង

ព្រៃធំ ខណ្ឌ ខាង ទិសក្សិណ។ យើង យល់ឃើញ ថា ទីនោះ នាំ មក នូវ សេចក្តីសុខកាយ និង ចិត្ត ពី ការវាយលុក ពី សំណាក់ ខ្មាំង សត្រូវរាជ្យ និងខ្មាំង សត្រូវ នគរ។ តើ អស់ ព្រះអង្គម្ចាស់ និង អស់ លោកនាម៉ឺន យល់ឃើញ បែបណាទៅ នូវ គម្រិះ របស់ យើង នេះ។

សុវណ្ណី (សំដី) ព្រះរាជា ទុក ដូច ជា បញ្ហា រួចស្រេច សំរាប់ ព្រះរាជ វង្សានុវង្ស និង អង្គអគ្គសេនាមាត្រ។ ដូច្នេះ ត្រូវ មានចម្លើយ តប ឱ្យស្របនឹង ព្រះរាជគម្រិះ ដើម្បី រក្សា សុខ សំរាប់ ការរស់ នៅ នៃ ជីវិត។ នៅ ក្នុង ទស្សនៈ បែបនេះឯង ដែល សម្តេច នាយក រាជគណរដ្ឋមន្ត្រី ឆ្លើយតបទៅ ព្រះរាជា ៈ

- ពួក យើងខ្ញុំ ជា អ្នកបំរើ យល់ឃើញ ថា ព្រះរាជគម្រិះ ព្រះអង្គ ពិត ជា នាំមក នូវ សេចក្តីសុខ ដល់ អាណាប្រជារាស្ត្រ គ្រប់ ស្រទាប់ និង ព្រះពុទ្ធសាសនា។ យើងខ្ញុំ ជា អ្នកបំរើ ហ៊ាន ប្តូរ ជីវិត មាន តែ ស្វាគមន៍ ដល់ ព្រះរាជគម្រិះ ជា ប្រយោជន៍ជាតិ នេះ។

អង្គប្រជុំ រាជគណរដ្ឋមន្ត្រី ព្រមព្រៀង ដូច្នេះហើយ ក៏ ចែក ចំណែក កិច្ចការ ដល់ ក្រសួង សាធារណៈការ អោយ ទៅរៀបចំ ទុកជាមុន នៅ ស្រុកសន្ធរ សំរាប់ទទួល ព្រះរាជា ដូច មាន សាង ព្រះបរមរាជវាំង ព្រះដំណាក់ ដោយខ្ចីខ្នា និងបន្ទាយជ័យឱ្យសម ឋានៈ ជា ព្រះរាជធានី នៃ ក្រុងកម្ពុជាធិបតេយ្យ។

# អ្នកតាឃ្លាំងមឿង

នៅ ស្រុកបាសាន (ស្រីសន្ធរ) មានមន្ត្រីធំម្នាក់ ឈ្មោះ ពិជ័យនាគ មាន ភរិយា ជា ស្រីពល ព្រះរតនត្រ័យ (ពល មាន មុខងារ ជា អ្នក ថែរក្សា វត្តអារាម)។ នាង បាន មាន កូនស្រីមួយ កើតនៅក្នុង រាជ្យ ព្រះធម្មរាជា មាន ឈ្មោះ ស។ បន្ទាប់ មក បាន មាន គភ៌ ម្ដងទៀត ហើយ ថ្ងៃ មួយ ជិត គ្រប់ ខែ នាង ចុះ ទៅ ដោះ ទុកសត្វ ក្នុង បង្គន់ ក៏ របូត ទារក នោះទៅ ក្នុង ទឹក។ ពេលនោះ មាន ហេតុ អស្ចារ្យ នាំ អោយ ឃើញ ថា ទារក នោះ មាន បុណ្យ មែន គឺ ថា វេលា នោះ ស្រាប់ តែ មាន ត្រីពោធំ មួយ មក ទទួល លេប ទារក នោះ ទៅ ក្នុង ពោះ បាត់ទៅ។ នៅ ពេល នោះ ព្រាន ប្រមង់ ម្នាក់ ទៅបង់ សំណាញ់ក៏ ត្រូវ ជាប់ ត្រីពោ នោះ បានមក។ ជា កុសល ទារក មិនស្លាប់។ ក្នុង ថ្ងៃ នោះ ក៏ មាន ហេតុ បណ្ដាល៙ សម្ដេច ពហរះ មហាសង្ឃរាជ (កាលនោះ នៅ ជា ព្រះសង្ឃសត្ថា) យប់ នោះផ្ទំ ស្កល់ទៅ យល់សប្ដិ ឃើញ ថា ដូច មាន ទេវ តាម ទូល ថា: ព្រឹក នោះ អោយ ស្ដេច យាង ទៅ កំពង់ទឹក ដើម្បី ជួយសង្គ្រោះ ទារកម្នាក់ ជា អ្នកមានបុណ្យ មាន វាសនា ផង។ លុះ តើន ឡើង សម្ដេច ក៏ ទ្រង់ នូវ ត្រៃចីវរ ចុះ គង់ក្នុងទូក ឱ្យ សិស្សានុសិស្ស អុំ ចេញ ទៅ។ ទ្រង់បិណ្ឌបាត តាមសព្វដង តែ ព្រះនេត្រ តែង គន់ រំពៃមើល ក្រែង មាន ហេតុ អ្វី ជា ចម្លែក ដ្បិត មាន និមិត្ត ពីយប់មិញ នោះ ដូច ជា ច្បាស់ ពេកណាស់។ លុះ សិស្ស អុំបន្តិច ទៅ ទូក ក៏ ទភ អែប ប្រប ទូក ព្រានប្រមង់នោះ។ សម្ដេច ឃើញ ត្រីពោ ក្នុង ទូក ព្រាន ប្រមង់ នោះ ធំប្លែក ស្ដេច ប្រឹង សង្កេត ទត ៙ ច្បាស់។

# អ្នកតាឃ្លាំងមឿង

ព្រានប្រមង់ ឃើញស្តេច អើត ទៅ ទត ត្រី នោះ ក៏ បង្កើត ឲ មាន សទ្ធា លើក ត្រីពោ ថ្វាយ ដល់ ព្រះអង្គ។ ព្រះអង្គ ទ្រង់ ទទួល ហើយ ក៏ ឲអុំ ទូក បិណ្ឌបាត ទៅ ទៀត។ លុះ បិណ្ឌ អស់ ពេលហើយ ស្តេច ក៏ យាង ត្រឡប់ មក អារាម វិញ។ ខណៈនោះ ស្តេច មាន ព្រះថេរ វាចា ថា ត្រីពោ នេះ ជា ពោជំប្លែក ពី ត្រី ពោ សព្វដង ប្រហែល ជា មាន ហេតុអ្វី ក្នុងពោះ ត្រី នេះ ជា ពុំ ខានឡើយ។ អស់ ពួក សិស្សានុសិស្ស ឮពុទ្ធដីកាហើយ ក៏ នាំ គ្នា យក កាំបិត ទៅ វះ ពោះ ត្រីនោះ, វះ ទៅ ឃើញ ទារក មួយ នៅ រស់។ ទើប ស្តេច ឲ កូននោះ ទៅ ប្តី ប្រពន្ធ មួយគូ យក ទៅ ចិញ្ចឹមរក្សា។

រឿង ចម្លែក នេះ បាន ឮ ដល់ ព្រះពិជ័យនាគ និង ភរិយា ក៏ នាំ គ្នា ទៅថ្វាយ បង្គំ ព្រះសង្ឃ សូមទារក ជា កូន នោះមក វិញ។ ពេល យក បាន ទារក មកផ្ទះវិញ ហើយ ក៏ នាំគ្នា សំរេច ដូរ ឈ្មោះកូន ពី កៅ ដែល ព្រះសង្ឃ ប្រគេន ឲ មក ជា កន វិញ។

តើ រឿងហេតុអស្ចារ្យ ដែល កើត មាន ឡើងនោះ មានទំនង ជា រឿង ពិត ដែរ ឬទេ ? យើងដឹងថា នៅក្នុង ព្រះរាជពង្សាវតាខ្មែរ វា មាន លក្ខណៈ ជា ប្រវត្តិសាស្ត្រ ផង និង រឿងព្រេង ផង។ ក្នុង ផ្នែក រឿងព្រេង បុព្វប្រវត្តិករខ្មែរ គាត់ និយម តែង បញ្ចូល បន្ថែម សំរាប់ បង្ហាញ នូវ ព្រឹត្តការណ៍ ឬ មនុស្ស ដែល ទុកជា រឿង ឬ បុគ្គល អស្ចារ្យ ដើម្បី ឱ្យ អារម្មណ៍ របស់ អ្នកអាន រស់នៅ ក្នុង រឿង ជាអច្ឆរិយៈ ដែល កម្រនឹងមាន នៅក្នុង លោកីយ។

# អ្នកតាឃ្លាំងមឿង

មួយវិញទៀត ផ្នែកនេះ ជា សិល្បវិជ្ជា របស់ អ្នកនិពន្ធ ដើម្បី ទុកជាសោភ័ណភាព នៃស្នាដៃ របស់ខ្លួន។ អ្វីដែល វាមិន ធម្មតា បើ ជា បុគ្គល គឺ ជា អ្នកមានបុណ្យ, បើ ជា ព្រឹត្តិការណ៍ គឺ ជា ការសំដែង នៃ នភាកាសភូត (phénomène céleste) ជា អំណោយផល មកក្នុង នរលោក (monde des humains) សំរាប់ ជា ការពឹងផ្អែកដល់ មនុស្ស ឬ អ្នកមានបុណ្យ នៅចំពោះមុខ បញ្ហា របស់ខ្លួន ដែល ខ្លួន ខ្វះ មធ្យោបាយ ជា មនុស្ស សំរាប់ ដោះស្រាយ។

នៅក្នុង សម័យនោះ របប នយោបាយ នៅស្រុកខ្មែរ ជា របប រាជាធិបតេយ្យ ដែល មាន មហាក្សត្រ ជា អ្នកដឹកនាំ ផ្តាច់ការ។ អ្វី ដែល ព្រះរាជា ចង់ បាន ឬ យល់ឃើញ មាន លក្ខណ: ជា រាជ តម្រិះបញ្ញា ជា និច្ច។ សម័យ ថ្ងៃ មួយ ព្រះបាទ ស្រីសុគន្ធបទ ទ្រង់ យាង ទៅ ថ្វាយ បង្គំ ព្រះ នៅ វត្ត, ពេលនោះ ទ្រង់ ទត ព្រះ នេត្រ ទៅ ឃើញ ស្រីម្នាក់ ឈរ នៅ លើ ខឿន ព្រះវិហារ ជា កូន ព្រះពិជ័យនាគ និង លោកស្រី មេបាន។ ព្រះអង្គ ទត ម្តងហើយ ម្តងទៀត នាំ ឲ ព្រះពិជ័យ ចាប់អារម្មណ៍ យល់ ដឹង ភ្លាម ពី ព្រះ រាជហឫទ័យ របស់ព្រះមហាក្សត្រខ្លួន ទើប ក្រោយ មក ក៏ ចូល ទៅ ក្រាប ថ្វាយ បង្គំ ព្រះរាជា ថ្វាយ កូនស្រីនោះ ជា ខ្ញុំ បំរើ ល្អង ធូលី ព្រះបាទ។ ព្រះរាជា ទ្រង់ សោមនស្សណាស់។ ទ្រង់ តាំង នាម នាង ស ជាអ្នក ព្រះម្នាង កេសរបុប្ផា ព្រះស្នំឯក ហើយ លើក ដំ កើង មាតា បីតា អ្នក ព្រះម្នាង អោយ មាន ឋានៈ ក្នុង រាជវង្សា

# អ្នកតាឃ្លាំងមឿង

នុវង្ស ក្នុង វង្សធំ មាននាមជា ព្រះបិតា ពិជ័យនាគ និង អ្នកព្រះមាតា មេបាន។

ដោយ មាន សេចក្តីប្រតិព័ន្ធ នឹង ព្រះស្នំឯក ពេក ព្រះបាទ ស្រីសុគន្ធបទ ទ្រង់ ព្រះបញ្ញត្ត អោយ លើកលែង ហៅ ស្រុកបាសានឱ្យ ហៅថា ស្រុកស្រី ស ឈរ ឬ ខែត្រ ស្រី ស ឈរ តែ ពាក្យ នេះយារៗមក ក៏ប្រែក្លាយ ជា ស្រុកស្រីសន្ធរ រហូត មក ដល់សព្វថ្ងៃនេះ។

## ស្តេចកន



បុត្រាមន្ត្រីម្នាក់នៅសម័យបូរាណ

តាំង ពី កុមារភាព កន ជា មនុស្ស មាន ប្រាជ្ញា ឈ្លាតវៃ ត្រូវបាន បិតា មាតា បញ្ជូន ឲ ទៅនៅក្តី ឬ រៀនសូត្រ នៅ វត្តអារាម ដែល មាន សម្តេច ពហរះ មហាសង្ឃរាជ ជា គ្រូ មាននាម សត្ថា។ លុះ ចម្រើន ធំ ឡើង មាន ចំណេះ លើ សិស្សានុសិស្សទាំងពួង ចេះ ស្ទាត់ សាស្ត្រមន្តវិជ្ជាការ គាថា កៅទណ្ឌ ក្បួនតម្រា ទាំងឡាយ គ្រប់ សព្វ សារពើ ឥត ចន្លោះ ឡើយ ហើយ ជាអ្នកជំនាញ ខាងបាច់ព្រួញ និង ពូកែ ហែលទឹក។ កន ចេះ

## អ្នកតាឃ្លាំងមឿង

បម្រើគ្រូ នាំឱ្យគ្រូ ពេញចិត្តនឹងសិស្ស ហើយ លោក បានទាយថា ៖ ក្មេងនេះ នឹង បាន គ្រង នគរ ថ្ងៃ ណាមួយ ជា មិនខាន។ ព្រះម្នាង កេសរបុប្ផា ជា បងស្រី របស់ កម្លោះ កន ឃើញ ប្អូន មាន ចំណេះ ក៏ស្នើ ដល់ ព្រះរាជា សូមឱ្យ ប្អូន ចូលខ្លួន បំរើ ព្រះអង្គ ហើយ ព្រះរាជា ក៏យល់ព្រម។ កន ជា មនុស្ស មាន ប្រាជ្ញា និង មាន ចំណេះ ចេះ ផ្គាប់ និង អាចជួយ ព្រះរាជា ក្នុង កិច្ចការ រាជការ គ្រប់បែបយ៉ាង ដែលនាំឱ្យព្រះអង្គ ស្រឡាញ់រាប់អាន ហើយ តាំងងារ ជា ‹អ្នកឧកស្នេហាចមចិត្ត› តែក្រោយមក ព្រះអង្គ ក៏មាន ព្រះរាជហឫទ័យ ចង់ តែងតាំង កន ជា មន្ត្រី នៅក្នុង ព្រះបរមរាជវាំង។ តែ ឧបសគ្គចម្បង គឺ ម្តាយ របស់ កន ជាប់ ជា ពលព្រះ គឺ ជា អ្នកងារ។ ទោះបី ព្រះអង្គ បាន ស្នើ ឱ្យ ម្តាយ ព្រះម្នាង កេសរបុប្ផា ដែលជា ម្តាយក្មេង របស់ព្រះអង្គ រួចខ្លួនពីងារ តែ ពួក មហាមន្ត្រី និង ព្រាហ្មណ៍ បុរោហិត រាំងរា ថា ព្រះរាជសំណើរនេះ វាផ្ទុយនឹង ព្រះពៃណីយ ផង និង ខុសពីសប្បថ របស់ព្រះបិតាផង ដែលបានប្រគល់ គ្រួសារនេះ ជា ពលព្រះ រួចទៅហើយ។ ដូច្នេះ ព្រះអង្គ រកងារថ្មីសំរាប់ដាក់ឱ្យ កន ឱ្យសម នឹង ការចេះដឹង, ងារនោះ គឺ ‹ឃុនហ្លួង ព្រះស្ដេច›។ នៅក្នុងមុខងារថ្មីនោះ កន មាន អំណាច ឱ្យស្រដី ត្រួតត្រា មើល ពល[15]បម្រើ ព្រះស្រីរតនត្រ័យ (ពលព្រះ) ទាំង

---

15 ពល ៖ ជាពូជមនុស្ស ដែលទុកជា វណ្ណៈ ថោកទាប ជាងគេបំផុត ឬ មនុស្ស ដែលមានទោសធ្ងន់ ហើយច្បាប់ តម្រូវឱ្យទុកមនុស្សនេះ តកូន

# អ្នកតាឃ្លាំងមឿង

អស់ ហើយ មាន ព្រះរាជអាជ្ញា ឱ្យផ្ដន្ទាយកទោស មនុស្ស ពាលា មោហ៍បិទ ចិត្តអកតញ្ញូ និង បង្កួចបង្ខុស ព្រះស្រីរតនត្រ័យ ល្មើស បុរាណប្រវេណី ចាស់ព្ដឹទ្ធាចារ្យផងទាំងពួង។

អំណាច របស់ កន នាំបង្កើត សេចក្ដីច្រណែន និង កំចោក[16] ពី សំណាក់ អស់ ព្រះបរមវង្ស និង មន្ត្រី ដែល តែងតែទុក ឃុន ហ្លួងព្រះស្ដេច ជា កូន ជាប់ ជា ពលព្រះ ជានិច្ច ហើយ ជា មនុស្ស ពុំកោតក្រែង មន្ត្រីចាស់ទុំ ខ្ញុំរាជការ ដោយអាងខ្លួន ជា ប្អូន របស់ព្រះស្នំឯក។ ដូច្នោះ ក៏នាំគ្នា ឃុបឃិត រក មធ្យោបាយ កម្ចាត់ នរជននោះ ឱ្យខ្ចាត់ចេញ ពីព្រះបរមវាំង។ រាល់ឱកាស ហុចឱ្យ អស់ស្ដេច, ព្រាហ្មបុរោហិត និង មន្ត្រី ដែល ជា សត្រូវចិត្ត របស់កន តែងតែ ក្រាបបង្គំទូល ដល់ ព្រះរាជា ជូនកាល ជា ការបង្កាច់បង្ខូច ឱ្យខូចកេរ្ដិ៍ របស់កន។ បន្តិចម្ដងៗ ព្រះរាជា ចាប់មាន អារម្មណ៍ ថា អ្វីៗ ដែល គេ ទូលថ្វាយ ជា ដំណឹង ជា ការពិត ហើយ ជា ពិសេស រឿង ទំនាយ របស់ គ្រូ របស់ កន ថា វា នឹងអាច ឡើងគ្រងរាជ្យសម្បត្តិ នៅពេល អនាគត។ ការណ៍ នោះ នាំឱ្យ ព្រះរាជា មាន កង្វល់ នៅក្នុង ព្រះរាជហឫទ័យ គ្រប់ ពេលវេលា រហូត ទ្រង់ ព្រះសុបិននិមិត្តឃើញថា មាន នាគមួយ ធំ មាន ឫទ្ធិមហិមា មកដេញព្រះអង្គ និង មនុស្សម្នា ឱ្យរត់ ចេញពីព្រះរាជវាំង ហើយព្រួសជាភ្លើង ឆេះដាលពេញទាំងព្រះ

---

តថៅរៀងទៅ។ ពល គឺ ជាពូជសូទ្រ: ក្នុងចំណោមវណ្ណ:ទាំងបួន នៃ ព្រហ្មញ្ញសាសនា គឺ ព្រាហ្មណ:, ក្សត្រិយ:, វៃស្ស: និង សូទ្រ:។

16 កំចោក : ធ្វើឱ្យក្ដៅក្រហាយ។

# អ្នកតាឃ្លាំងមឿង

មហានគរ។ លុះព្រឹកឡើង ព្រះរាជា ចេញព្រះរាជរោងរម មាន ព្រះអនុជ ព្រះចន្ទរាជា ព្រាហ្មព្រឹទ្ធាចារ្យ សេនាបតី មន្ត្រី តូចធំ ចូលគាល់គ្រប់ដំណែង ដើម្បី ពិភាក្សា កិច្ចការ នគរ។ ខណៈ នោះ ស្ដេច ទតឃើញ មានតួនាគពីរ ព័ទ្ធពន្ធ័ លើ យុនលួងព្រះ ស្ដេច ហើយ វា ងើបក្បាលឆ្វេងស្ដាំ ទន្ទឹមគ្នានឹងក្បាល យុនព្រះ ស្ដេចកន មាន កិរិយា ហាក់ដូចជា នឹងស្ទុះ ទៅខាំព្រះអង្គ។ នាគ ដែល ព្រះអង្គ ទតឃើញនោះ វាដូចនាគ ដែល ព្រះអង្គ ទ្រង់ ព្រះសុបិននិមិត្ត កាលពីយប់មិញ។ នៅពេល ព្រះសវនាការ នោះដែរ មាន សំបុត្រប្ដឹង ពីចៅហ្វាយ ស្រុកបាត់ដំបង ថា ព្រះ ទឹក សំរាប់ ព្រះមហាក្សត្រ ដែលនៅក្នុង គុហាភ្នំបាណន់នោះ ចេញឈាមដាលក្រហម ដូចទឹកល័ខ។ ក៏មាន សំបុត្រប្ដឹង ពី ចៅហ្វាយ ស្រុកបាភ្នំ ថា ព្រះពុទ្ធរូបក្នុង ទីបាភ្នំ ហូរទឹកព្រះនេត្រ ជា ឈាម ដូចល័ខដែរ, ហើយ ព្រះចៅអធិការ វត្តព្រះវិហារសួគ៌ ក៏មានសង្ឃដិកា ថា ព្រះជ្រៃប្រថ្នូលនភ បាក់មែកចេញជា ឈាម ព្រមទាំង ព្រះឥសូរ ព្រះនរាយណ៍ ប្រេះព្រះឧរា ចេញជា ឈាមដែរ។ ចំណែក ព្រះគ្រូបុរោហិត ក៏ថ្វាយសេចក្ដី ថា ព្រះខាន់ ជ័យមង្គលនោះ មាន ស្នឹមក្រហម ពីត្រីសូលិ៍ ដល់គល់។ លុះផុត ព្រះសវនាការ ព្រះរាជា ទ្រង់ ប្រិក្សាការណ៍ ជា សម្ងាត់ ជាមួយ ឥស័ភ័ទ្ទ ជា មហាគ្រូ និង រាជហោរាធិបតី ស្ដីពី បាតុភូត ដែល មាន កើតឡើង នៅក្នុង ព្រះនគរ និង ព្រះសុបិននិមិត្ត របស់ ព្រះអង្គ។ អ្នកទាំងពីរ ក្រាបទូលថា ព្រះអង្គ ច្បាស់ជានឹងមាន រាជសត្រូវ បើតាម លេខតម្រា គឺត្រូវត្រង់ យុនហ្លួងព្រះស្ដេចកន

# អ្នកតាឃ្លាំងមឿង

តែម្តង ដ្បិត តារារាសី របស់វា កំពុងឡើងខ្លាំងណាស់ ព្រោះ វាកើត ឆ្នាំ នាគ។ បន្ទាប់មក អ្នកទាំងបី ក៏នាំគ្នា រកមធ្យោបាយ សម្លាប់ យុនហ្លួងព្រះស្តេចកន កុំឱ្យមាននរណាសង្ស័យ ថា ជាឃាតកម្ម។ ឧបាយកលមួយ ដែល អ្នកទាំងបី យល់ឃើញ ថា វាមាន ប្រសិទ្ធិភាព ហើយ លាក់អាថិកំបាំងផង គឺ ការក្លែង ទៅបង់សំណាញ់ ហើយក្លែង ធ្វើជាសំណាញ់ ជាប់គល់ រួចហើយបង្គាប់ឱ្យកន មុជដុះទៅដោះ។ លុះមុជក្នុងទឹកហើយ យើងពួតគ្នាបង់សំណាញ់ គ្របឱ្យជាប់ទាំងដៃជើង វានឹងឡើងមិនរួច ហែលក៏មិនបាន ដូច្នេះ វា គង់តែស្លាប់ដោយងាយ។ តែឧបាយកលនោះ ត្រូវបាន ព្រះស្នំឯក ជា បងស្រី កន លួចស្តាប់ឮសំដី ថា ឱ្យព្រះស្តេចកន មុជទឹក ហើយ បង់សំណាញ់គ្របឱ្យស្លាប់ តែមិនបានឮ ថា ប្អូនខ្លួន ខុសពីហេតុអ្វី នោះឡើយ។ លុះស្អែកឡើង ព្រះស្នំឯក ក៏បានទទួលព្រះបញ្ជា ពីព្រះរាជា ឱ្យដង្ហែព្រះអង្គ ទៅបង់សំណាញ់ ជាមួយ អស់មន្ត្រីរាជការ។ ព្រះជលដំណើរ កំសាន្តនេះ វា ធ្វើឱ្យ ព្រះស្នំ មាន ចិត្តថប់បារម្ភនឹងប្អូន ពុំស្រាកស្រាន្តសោះ ក៏តាំងសរសេរជាអក្សរ រាយសេចក្តីដែលខ្លួន បានឮ ប្រាប់ប្អូន ឱ្យប្រុងប្រយ័ត្នមែនទែន។ ដឹងការណ៏នេះហើយ យុនហ្លួងព្រះស្តេចកន មាន ការតូចចិត្ត ជា ខ្លាំងព្រោះខ្លួន មិនដែល ប្រព្រឹត្តិ កំហុស អ្វីទាល់តែសោះ ចំពោះ ព្រះរាជា មានតែ ខំបំរើព្រះអង្គ ដោយស្មោះសរ, ចុះហេតុអ្វី ក៏ព្រះអង្គ មាន ព្រះរាជបំណង ចង់សម្លាប់ខ្លួន ទៅវិញ ? សំនួរនេះកន សួរហើយ សួរទៀត នៅក្នុង ចិន្តា របស់ខ្លួន ហើយ ជូនកាល

ក៏គួរមិនអាចជឿបាន។ លុះដល់ពេល ដែលទទួលព្រះរាជា ឱ្យមុជទឹក ទៅដោះសំណាញ់ ទើបភ្ញាក់ខ្លួនថា ជា រឿងពិត។ ត្រូវដឹងថា កន ជា មនុស្សពូកែ ហែលទឹកណាស់ តាំងពីកុមារភាពមកម្លេះ ហើយ នៅពេលដែល កន លោតទៅក្នុងទឹកភ្លាម គាត់មុជហែល បញ្ឆោសទិស ដែល ព្រះរាជា ចង្អុលប្រាប់ សំដៅ ទៅកន្លែង ដែល មាន ត្រឹប[17] ច្រើន រួច ក៏ពួន ពីកន្លែងមួយ ទៅកន្លែងមួយទៀត ទម្រាំយប់នឹងរត់ទៅទៀត។ រីឯ ព្រះរាជា និងពួក ស៊ុមត្រលុំ នៅពេលឃើញ កន មុជក្នុងទឹក គិតតែនាំគ្នាបង់ សំណាញ់ ត្រួតច្រើនជាន់ ទៅទីកន្លែង ដែល សំណាញ់ ព្រះរាជា ក្រវែង ហើយ ស្រែកប្រាប់កន ថា សំណាញ់អញជាប់អ្វីនៅក្នុងទឹក ហើយ ឱ្យ កន មុជទឹក ទៅដោះ។ រួចហើយ នាំគ្នារង់ចាំមួយស្របក់ ដោយ នាំគ្នានឹកគិតថា ច្បាស់ ជា កន ថប់ដង្ហើមស្លាប់ នៅក្នុង ទឹក ជា ពុំខាន។ តែក្រោយបន្តិចមក ក៏នាំគ្នាលើកសំណាញ់ឡើង តែ ពុំឃើញ សព កន នោះឡើយ, ខណៈនោះព្រះរាជា ក៏បញ្ជា ឱ្យជលសេនា មុជ ក្នុងទឹក ស្វែងរក សព កនតែ រកពុំឃើញសោះ។ ស្តេចរឹងព្រួយព្រះទ័យណាស់ ទ្រង់ត្រាស់ថា ‹‹អានេះរត់រួចទៅ ដូចជាខ្លារួចពីទ្រុង វាគង់នឹងត្រឡប់មកសងសឹកវិញជាពុំខានឡើយ››។

---

17 ត្រឹប : ព្រៃអណ្តែត គឺព្រៃដែលកើតលើទឹក ដោយស្មៅ ឬ ត្រាវ, ត្រកៀត, បបុស ស្បូវ ដុះលើមមោកចក មមោកកំពឹងពួយ។

# អ្នកតាឃ្លាំងមឿង

ដូចព្រះអង្គ គិតស្មានទុកមែន, កន ជា មនុស្សប្រាជ្ញា មាន ចំណេះ មាន កេរ្តិ៍ឈ្មោះ ល្បីល្បាញ ខ្លាំងពូកែ នៅក្នុង ចំណោម អស់ពលព្រះ, អ្នកងារ និង រាស្ត្រក្រីក្រ ក៏ អាចប្រមូលផ្តុំ អស់ពួក ទាំងនោះ បង្កើត ជា កងទ័ព រួចវាយប្រហារ កងទ័ពភូមិន្ទ រហូត មាន ជ័យជំនះ ហើយ ព្រះបាទស្រីសុគន្ធបទ ទ្រង់ ក៏ សុគត នៅក្នុង សមរភូមិ ផងទៀត នៅឆ្នាំ ១៥១២ ក្នុង ព្រះជន្ម ៣៤ ឆ្នាំ នៅក្នុង បន្ទាយ ស្ទឹងសែន នៅខេត្ត កំពង់ធំ[18]។ ស-ង្គ្រាម រវាង ស្តេចកន និង ព្រះស្រីសុយគន្ធ មាន រយៈពេល ៤ ឆ្នាំ។ នៅក្នុង សង្គ្រាមនោះ ទាំងសងខាង មានប្រើ គ្រប់ល្បិច យុទ្ធសាស្ត្រ និង ចិត្តសាស្ត្រ ដ៏អស្ចារ្យ (សូមអាន ឯកសារ មហា បុរសខ្មែរ សរសេរ ដោយ លោក អេង សុត)។ ត្រូវដឹងថា ព្រះស្រី សុគន្ធបទ ទ្រង់ ចាញ់ កលល្បិច ស្តេចកន ត្រូវបាន កងពិសេស របស់កន ២០០ នាក់ ចូលទៅធ្វើឃាតព្រះអង្គ នៅក្នុង ព្រះរាជ តំណាក់តែម្តង។

យុនហ្លួងព្រះស្តេចកន ឡើងគ្រងរាជ្យសម្បត្តិ បន្ត ពី ព្រះស្រី សុគន្ធបទ ក្នុង ព្រះជន្មាយុ ២៩ ឆ្នាំ ក្នុង វាំងបាសាន ខែត្រស្រី សឈរ (ស្រីសន្ធរ), ទ្រង់ ជ្រើសរើស យក ព្រះនាមរាជ្យ ថា «ព្រះ ស្រីជេដ្ឋារាជ»។ បន្ទាប់មក ព្រះអង្គ ប្តូរ រាជធានី ពី បាសាន ទៅ តាំងនៅ ចុងខែត្រត្បូងឃ្មុំ ទល់ដែនខែត្របាភ្នំ ក្នុង ភូមិ

---

18 ខេត្តកំពង់ធំ ដើមឡើយឈ្មោះ ខេត្តសន្ទុក នៅពេល ស្តេចកន ឈ្មះ សង្គ្រាម ដូរឈ្មោះថា ខេត្តកំពង់ស្វាយ, បច្ចុប្បន្ន ឈ្មោះ ខេត្ត កំពង់ធំ។

# អ្នកតាឃ្លាំងមឿង

ស្រឡប់ ហៅថា ‹‹ក្រុងសន្លប់ដូនតី ព្រៃនគរ[19]››។ ព្រះស្រីជេដ្ឋារាជ ទទួល មរណៈ នៅឆ្នាំ ១៥២៥ ដោយ ច្បាំងចាញ់ ព្រះចន្ទរាជា ជា ព្រះអនុជ ព្រះស្រីសុគន្ធបទ។

## ព្រះចន្ទរាជា

ព្រះចន្ទរាជា ជា មហាឧបរាជ ត្រូវបាន ព្រះជេដ្ឋា ឱ្យទៅគង់នៅក្នុង ក្រុងចតុមុខ មណ្ឌលស្រុកភ្នំពេញ (រាជធានីភ្នំពេញ សព្វថ្ងៃនេះ) ឱ្យបានជាទីកោតក្រែង អ្នកត្រើយខាងលិច ដើម្បីទំនុកបំរុង អ្នកស្រុក ឱ្យបានក្សេមក្សាន្ត ឥតមាន កលិយុគ។ នៅពេល ដែលមាន ផ្ទុះសង្គ្រាមភ្លាម រវាង ព្រះស្រីសុគន្ធបទ ជាមួយស្តេចកន នៅឆ្នាំ ១៥០៨ ព្រះចន្ទរាជា មាន ព្រះជន្មាយុ ២៤ ឆ្នាំ។ ព្រះចន្ទរាជា លុះ ឮពាក្យ និង ដឹង ដំណឹង ថា យុនហ្លួងព្រះស្តេចកន មាន បញ្ជា ពី ព្រះជេដ្ឋា ឱ្យកេណ្ឌរាស្ត្រ បង្កើត កងទ័ពដើម្បី ច្បាំងនឹងទ្រង់ ព្រោះ តែ ទ្រង់ មានគំនិតក្បត់នឹងព្រះមហាក្សត្រ ហើយ ពាក្យចចាមអារ៉ាមនេះ មិនដែល មានដំណឹងបដិសេធ ពី ព្រះជេដ្ឋា ក៏នឹងគិតថា រឿងនេះ ជា រឿងពិតមែនហើយ។ ទ្រង់ ក៏មាន ព្រះចិន្តា ថា ៈ ណ្ហើយចុះ បើព្រោះតែយើងមួយ យើងនឹងនៅ ឱ្យគេទើសទាល់រវល់ថ្វី។ ទើប ស្តេច នាំ អស់បណ្តាជាខ្ញុំ ៥០ នាក់ ដោះរត់ជើងគោក ទាំងរាត្រីនោះ ពីក្រុង

[19] ក្រុងនេះសព្វថ្ងៃនៅក្នុងឃុំដូនតី ស្រុកត្បូងឃ្មុំ ក្នុងខេត្ត ត្បូងឃ្មុំ។

# អ្នកតាឃ្លាំងមឿង

ចតុមុខ ស្រូតរូតចូលទៅក្រុងទេពបុរីទៅ (ស្រុកសៀម)។ តើហេតុផល ដែល ព្រះចន្ទរាជា លើកឡើង វា សមដែរឬទេ ?

នៅលើចំណុចនេះហើយ ដែល យើងឃើញថា បង និង ប្អូន មិនត្រឹមតែ គ្មានទាល់តែសោះ ទំនាក់ទំនង កិច្ចការរាជការ ជាប្រក្រតី ថែមទាំង មាន វិមតិសង្ស័យនឹងគ្នា មិនដាច់ស្រេច។ សួរថា តើ ព្រះស្រីសុគន្ធបទ ជា មនុស្ស គិតតែខ្វល់ចិត្តនឹងការក្បត់ ដែល នាំឱ្យកើតហេតុ ជាមួយ ឃុនហ្លួងព្រះស្ដេចកន ហើយ មាន សេចក្ដីសង្ស័យ ជានិច្ច ទៅលើ ព្រះអនុជ ដែល នាំឱ្យ ទ្រង់ រត់ចោល ព្រះរាម នៅពេលមានអាសន្ន ? ឬ ព្រះចន្ទរាជា ជា មនុស្សកំសាក រត់ភៀសខ្លួន ព្រោះ ខ្លាច កន ដ្បិត ទ្រង់តែងតែឮគេ និយាយ អំពី បារមី នៃ ជននេះ ? ទោះបី នៅក្នុងករណី បែបណាក៏ដោយ ការភៀសខ្លួន របស់ ព្រះចន្ទរាជា ទៅស្រុកសៀម ជាអំពើមួយដែលគេ អាចចាត់ទុកបានថាជា ស្ដេចកំសាកផង និង ក្បត់ ព្រះមហាក្សត្រផង ហើយនឹងក្បត់ព្រះរាមផង ព្រោះ ខ្លួន បោះបង់ រាជកាតព្វកិច្ច ដែល ជា អ្នករក្សា សន្តិសុខ នៅត្រើយខាងលិច ដែល ជា ដំបន់ ដែល កន ធ្វើសកម្មភាពឧទ្ទាមកម្ម ប្រឆាំងនឹងរាជវង្ស របស់ទ្រង់។ ក្រោយពីបាន ទៅរស់នៅ សូមជ្រកកោននឹង ព្រះចៅសៀម អស់រយៈពេល ច្រើនឆ្នាំមក ព្រះចន្ទរាជា ទ្រង់ ក៏មាន ព្រះរាជហឫទ័យចង់វិលត្រឡប់ មកស្រុកខ្មែរវិញ ក្នុងគោលដៅ ច្បាំង តតាំងនឹង ព្រះស្ដេចកន ដើម្បី ប្រត្យាស្ថាបនា រាជវង្ស ពេញត្រកូល

# អ្នកតាឃ្លាំងមឿង

(monarchie légitime) ឡើងវិញ។ នៅឆ្នាំ ១៥១៥ ទ្រង់ ក៏ប្រើល្បិចកល សូមទ័ពស្តេចសៀម ចំនួន ៥ ពាន់នាក់ ប្រដាប់ដោយ អាវុធយុទ្ធភ័ណ្ឌ និង ដំរី ១ ពាន់ ក្បាល ដើម្បី ទៅទាក់ដំរី ស ថ្វាយព្រះអង្គ។ ព្រះចៅសៀម មិនត្រឹមតែ ផ្តល់ នូវ កងទ័ពសង្គ្រាម, ទ្រង់ប្រគល់ ព្រះសែង[20]អាជ្ញាសឹក ថែមទៀត ដល់ ស្តេចខ្មែរ។ ជាមួយ កងទ័ពនោះឯង ដែល ព្រះចន្ទរាជា វិលចូលស្រុកខ្មែរ ហើយ ស្វែងរក ជំនួយ ពី ធនិន (មហាសេដ្ឋី) និង ក៏ជា មេស្រុកម្នាក់ដែរ នៅ ខែត្រពោធិសាត់ ឈ្មោះ តាមឿង ដែល ធ្លាប់ ទទួល បន្ទុក ព្រះអង្គ កាល ទ្រង់ ភៀសខ្លួន យាងចេញពីស្រុកខ្មែរ ទៅស្រុកសៀម។ ចាប់ពី ខេត្តពោធិសាត់នោះឯង ព្រះចន្ទរាជា រៀបចំ កងទ័ព ខ្មែរ-សៀម ហើយ ធ្វើសង្គ្រាម តទល់នឹង កងទ័ព ស្តេចកន អស់រយៈពេល ១០ ឆ្នាំ ទើប ទ្រង់ ទទួលបាន ជ័យជំនះ ហើយ សម្លាប់ ព្រះស្តេចកន បាន នៅឆ្នាំ ១៥២៥។ នៅឆ្នាំ ១៥២៨ ព្រះចន្ទរាជា ទ្រង់ ប្តូរ រាជធានី ពី ខែត្រពោធិសាត់ មកតាំងនៅ បន្ទាយ លង្វែក។

វិបុលមធ្យោបាយ[21] ដែល ព្រះចៅសៀម ថ្វាយ ព្រះចន្ទរាជា វាអាចសួរ ជា សំនួរ ថា តើ មាន សមគ្គចេតនា[22] រវាង ព្រះចៅសៀម ជាមួយ ព្រះចន្ទរាជា ដើម្បី ច្បាំងនឹង កន ជា រាស្ត្រ និង

---

20 ព្រះសែង : ដាវ។
21 វិបុល : គុ. ច្រើនក្រៃ, បរិបូរ។
22 សមគ្គចេតនា : គំនិតព្រមព្រៀង។

# អ្នកតាឃ្លាំងមឿង

ជា អន្តមនុស្សជាតិ[23] ផង ឡើងគ្រងរាជ្យ ដែលនាំឱ្យ ខូចកេរ្តិ៍ឈ្មោះ ដល់ វណ្ណៈក្សត្រិយ: ដែរឬទេ ? សមគ្គភាព វា អាចមាន ព្រោះ រាជវាំង (cour royal) សៀម តាំងពីសម័យ ព្រះធម្មរាជា (១៤៧៨-១៥០៤) មក គេ តែងទុក ស្រុកខ្មែរ ជា នគរចំណុះ ដូច្នេះ ព្រះចៅសៀម ទ្រង់ទុក ស្តេចកន ជា សត្រូវ វណ្ណៈ និង ជាឧទ្ទាមកម្ម ផង នឹងក្រុងទេពបុរី ព្រោះ ស្តេចកន ឡើង គ្រងរាជ្យ ដោយ គ្មាន ការអនុញ្ញាត ពី រាជវាំងសៀម។ បន្ទាប់ពី ព្រះចន្ទរាជា ឡើង គ្រងរាជសម្បត្តិ អស់មួយរយៈកាល, ព្រះចៅសៀម ក៏ចាត់ មហាមន្ត្រីទូត នាំព្រះរាជសារ ដើម្បី ទាមទារឱ្យហ្លួងខ្មែរ ថ្វាយ សួយសារអាករ ដល់ ព្រះចៅសៀម ជាសំណង នៃជំនួយ ដែល ព្រះអង្គ បានជួយដល់ ព្រះរាជាខ្មែរ។ ប៉ុន្តែ ព្រះចន្ទរាជា បដិសេធ ដោយលើកហេតុផល ថា ខ្មែរ ក៏ធ្លាប់ជួយសៀមច្រើនដងដែរ ហើយ ជំនួយ ដែល សៀម ថា ជួយ ដើម្បី ច្បាំងនឹងស្តេចកន ក៏ពុំមាន អាការ ជាកម្លាំងសឹក នោះដែរ។ ជ័យជំនះ គឺ ដោយសារ កម្លាំងខ្មែរ សុទ្ធសាត ដូច្នេះ វា គ្មាន ហេតុផលអ្វី ដែល ខ្មែរ ត្រូវ ជំពាក់គុណសៀម នោះឡើយ។ ការបដិសេធនោះ នាំឱ្យ ព្រះចៅសៀម ព្រះចៅចក្រពត្រ មាន កំហឹងខ្លាំង ក៏បញ្ជាឱ្យលើកទ័ព មកច្បាំងនឹងខ្មែរដឹកនាំដោយព្រះអង្គផ្ទាល់។ កងទ័ព ព្រះចន្ទរាជា និង ព្រះចៅចក្រពត្រ ចូលច្បាំងគ្នា នៅមហានគរ។ តែ ទ័ពសៀម បរាជ័យ រត់ខ្ចាត់ខ្ចាយអស់។ ប៉ុន្តែ

---

23 អន្តមនុស្សជាតិ : មនុស្ស មានដើមកំណើត ទាបថោក។

# រឿងតាឃ្លាំងមឿង

នៅក្នុង ព្រះរាជពង្សាវតារ ភាគបី គ. ៥៣-៣ មាន សេចក្ដីថា ព្រះចៅសៀម បន្ទាប់ពី ទទួល បរាជ័យ បានបញ្ជាឱ្យ ចៅពញា អុង ឱ្យលើកទ័ពមកច្បាំងនឹងខ្មែរ ម្ដងទៀត។ ពញា អុង នេះ ជា បុត្រា អតីត ព្រះមហាក្សត្រខ្មែរ ព្រះនាម ស្រីរាជា (១៤៣៣-១៤៨៥) ដែល ព្រះចៅសៀម ចាប់យក ទៅស្រុកសៀម ដោយសារ ព្រះអង្គ ចាញ់បោក ព្រះធម្មរាជា ជា ព្រះអនុជ។ នៅពេលនោះ ស្ដេចសៀម អនុញ្ញាតឱ្យ ព្រះស្រីរាជា យក ពញា អុង ជា បុត្រ ទៅតាម ហើយ ព្រះរាជកុមារខ្មែរនេះ ត្រូវបាន ស្ដេចសៀម លើកដំកើង កិត្តិយស ជា ព្រះរាជបុត្រធម៌ ហើយក្រោយមក ផ្សំផ្គុំ ជាមួយនឹងបុត្រី របស់ព្រះអង្គ។

នៅពេល ដឹងថា ទ័ពសៀម ដឹកនាំដោយ ពញា អុង, ព្រះចន្ទរាជា ផ្ញើព្រះរាជចុតហ្មាយមួយច្បាប់ ថ្វាយដល់ ពញា អុង មាន សេចក្ដី ថា៖ សម្ដេច ព្រះរាម យាងមកនេះ គឺប្រាថ្នា យកមហាស្វេតឆ័ត្រ ក្រុងកម្ពុជា ថ្វាយស្ដេចសៀម ជាប្រយោជន៍ នឹងមិនឱ្យ វង្សក្រស័ត្រ កម្ពុជា នៅឯករាជ្យ ព្រោះ សៀម ប្រកបដោយ នូវ លោភចេតនា ប្រាថ្នាឱ្យ ក្រុងកម្ពុជា នៅក្នុង អំណាច របស់ខ្លួន។ ឥឡូវ ព្រះរាម បើខ្ញុំអនុជនឹងតយុទ្ធ ដោយ នូវសេនាទាហាន បើទុកជា ឈ្នះឬចាញ់ ក៏មិនប្រសើរដែរ ព្រោះ យើងទាំងពីរ ជា មហាក្រស័ត្រ មាន វង្ស តែមួយ ជាមួយគ្នា ហើយតាំងព្រះទ័យថា នឹងយកជ័យជំនះ ដោយសព្វខ្លួន។ ខ្ញុំអនុជ សុំប្រជល់ដំរី តែព្រះអង្គនឹងព្រះអង្គ ឱ្យនាយកង នាយទ័ពមើល។

អំណើះតទៅ គ្មាន ក្រស័ត្រណា ហ៊ានក្លា ចេញជល់ដំរី ដូចខ្ញុំ អនុជ និង ព្រះរាមឡើយ។ បើព្រះអង្គ មានជ័យជំនះ ខ្ញុំអនុជ នឹងថ្វាយ ព្រះមហាឆ្វេតឆ័ត្រ បើ ព្រះរាម បរាជ័យ ឱ្យថយទៅ ប្រាប់ស្តេច សៀម កុំឱ្យលោភ ពីព្រោះ ក្រុងទេពបូរី និង កម្ពុជា មាន ខណ្ឌសីមា ដោយឡែកពីគ្នា តាំងពីបុរាណរៀងមក។ បើ សម្តេចព្រះរាម ជ្រាបហើយ ទ្រង់ពុំសព្វព្រះទ័យ ឱ្យស្តេចត្រឡប់ទៅ ស្រុកសៀមវិញ ហើយ ឱ្យស្តេចសៀម រើស នាយទ័ព ក្នុង វង្សក្រស័ត្រ ឱ្យចេញមកជល់ដំរី ឱ្យឃើញថ្វីដៃ។ បើព្រះរាម សព្វព្រះទ័យ សុំឱ្យ ឆ្លើយ កំណត់ថ្ងៃ និង វេលា ទៅដល់ខ្ញុំអនុជ។

ពញា អុង យល់ព្រមតាមសំណើរ របស់ ព្រះចន្ទរាជា។ ស្តេចទាំងពីរអង្គ គង់លើដំរីសឹក រៀងៗខ្លួន, ក៏នាំគ្នាបញ្ជាឱ្យ ដំរីប្រជល់គ្នា ហើយ រៀងៗខ្លួន វាយប្រហារគ្នាផង ដោយ ប្រើ ដាវ និង លំពែង គ្រប់ក្បាច់ សិល្បយុទ្ធ អស់មួយរយៈពេល បន្តិចក្រោយមក ពញា អុង ភ្លាត់ស្នៀត ត្រូវបាន ព្រះចន្ទរាជា កាប់ត្រូវ ហើយ ធ្លាក់ពីដំរីស្លាប់តែម្តង។ ទ័ពសៀម ឃើញថា នាយទ័ពខ្លួន ធ្លាក់ពីដំរី ក៏ ស្រែកហ៊ោ ហើយ សម្រុក វាយប្រហារទ័ពខ្មែរ តែត្រូវ ខេមរទាហាន វាយតបវិញ រហូត ទទួលបានជ័យជំនះ ជា ស្ថាពរ[24]៕

24 នៅពេលដែល ព្រះចន្ទរាជា រៀបនឹងចាកចេញពីស្រុកសៀម ទ្រង់ បានទៅបបួល ដោយ សម្ងាត់ ពញា អុង តែ ទ្រង់ ឆ្លើយថា : អូនអើយ បងមករស់នៅក្រុងទេពនេះ ជាឈ្លើយព្រះពុទ្ធចៅទេ តែព្រះអង្គ ពុំយកទោសបង ស្តេចប្រោសបង ឱ្យបងគ្រង ស្រុកសុវណ្ណខាក់លោកនេះ ជាខែត្រធំស្មើនឹងព្រះរាជាបុត្រទៅហើយ។ បងបានប៉ុណ្ណោះហើយ បងក៏បានសុខណាស់ហើយ។ បើបង បានសុខដូច្នេះហើយ បងនឹងគិតរក សុខឯណាទៀត។ ចំណែកឯ ស្រុកខ្មែរវិញ បង លែងនឹករលឹកអាឡោះអាល័យហើយ តាមតែអ្នកអូនគិតគួរចុះ...។